
ការតាមដាន ផ្កាថ្ម
សំរាប់
ការគ្រប់គ្រង

# ការតាមដានផ្កាថ្ម
# សំរាប់
# ការគ្រប់គ្រង


និពន្ធដោយៈ

លោក Andre J. Uychiaoco

លោក Stuart J. Green

លោក Margarita T. dela Cruz

លោក Paulyn A. Gaite

លោក Hazel O. Arceo

លោក Porfirio M. Alino

លោក Alan T. White

បកប្រែជាភាសាខ្មែរដោយៈ

លោក ស៊ុយ សេរីវឌ្ឍន៍

លោក បួយ រតនា

លោក ហិប សុខាន់ណារ៉ូ

លោក កៅ មុនីរិទ្ធ

កែសំរួលជាភាសាខ្មែរដោយៈ

លោក អ៊ុច ទ្រី

លោក គឹម សួ

# ការតាមដានត្រួតពិនិត្យ ផ្កាថ្ម
## សំរាប់
# ការគ្រប់គ្រង


អានដ្រេ អូអ៊ីឈីអាកូ (Andre J. Uychiaoco)

ស្ទូអាត គ្រីន (Stuart J.Green)

មាការីតា ដឹឡាគ្រូស (Margarita T dela Cruz)

ប៉ូលីន ហ្គាយ (Paulin A Gaite)

ហាសេល អាសេអូ (Hazel O. Arceo)

ប៉ូហ្វ៊ីរីអូ អាលីណូ (Porfirio M. Alino)

អាឡេន វ៉ាយ (Alan T. White)

Marine Science Institute
Marine Environment & Resources Foundation, Inc.
University of the Philippines, Diliman

Guiuan Development Foundation, Inc.
University of the Philippines in the Visayas, Tacloban

Voluntary Service Overseas - Philippines,
Bohol Integrated Development Foundation, Inc.



Through support from

United Nations Development Programme
Global Environment Facility-Small Grants Program

Coastal Resource Management Project of the Department of Environment and Natural Resources supported by the United States Agency for International Development

University of the Philippines Center for Integrative & Development Studies

Printed with assistance from

Fisheries Resource Management Project

Department of Agriculture - Bureau of Fisheries and Aquatic Resources

Asian Development Bank

Japan Bank for International Cooperation

# ការតាមដានត្រួតពិនិត្យ ផ្កាថ្ម សំរាប់ ការគ្រប់គ្រង


អានដ្រេ អូអ៊ីឈីអាកូ (Andre J. Uychiaoco), ស្ទូអាត គ្រីន (Stuart J.Green), មាការីតា ដឺឡាគ្រូស (Margarita T dela Cruz), ប៉ូលីន ហ្គាយ (Paulin A Gaite), ហាសេល អាសេអូ (Hazel O. Arceo), ប៉ូហ្វីរីអូ អាលីណូ (Porfirio M. Alino), អាឡេន វ៉ាយ (Alan T. White)



បោះពុម្ពលើកទី មួយ ឆ្នាំ ២០០១។ បោះពុម្ពនៅ ទីក្រុងសេបូ ប្រទេស ហ្វីលីពីន



ចំលងត្រឹមត្រូវ ឆ្នាំ ២០០១។ សៀវភៅនេះអាចចំលងដោយគ្មានការកែប្រែ និងចែកផ្សាយដោយ រក្សាទុកការរក្សាសិទ្ធច្បាប់ដើម និងចំណង ជើងទំព័រ។ ការបកប្រែ និង រក្សាទុកជាកម្មសិទ្ធ នៃសៀវភៅនេះត្រូវបានលើកទឹកចិត្ត។ ទោះបីជាយ៉ាងណាក៏ដោយ គ្មានផ្នែកណាមួយនៃសៀវភៅនេះត្រូវបានបកប្រែ ឬយកធ្វើជាកម្មសិទ្ធិ ដោយគ្មានការអនុញាតិពិ អ្នក និពន្ធណាមួយ ក្នុងចំណោមឈ្មោះទាំងបីខាងដើម។



គុណកថា: អានដ្រេ អូអ៊ីឈីអាកូ (Andre J. Uychiaoco), ស្ទូអាត គ្រីន (Stuart J.Green), មាការីតាដឺឡា គ្រូស (Margarita T dela Cruz), ប៉ូលីន ហ្គាយ (Paulin A Gaite), ហាសេល អាសេអូ (Hazel O.Arceo) ប៉ូហ្វីរីអូ អាលីណូ (Porfirio M. Alino), អាឡេន វ៉ាយ (Alan T. White) ឆ្នាំ២០០១។ ការតាមដានត្រួតពិនិត្យ ផ្កាថ្ម សំរាប់ការគ្រប់គ្រង។ មហាវិទ្យាល័យប្រទេសហ្វីលីពីន វិទ្យាស្ថានវិទ្យាសាស្ត្រសមុទ្រ, កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិមូលនិធិសំរាប់អភិវឌ្ឍន៍របស់ហ្គូអាន (Guiuan) សេវាអ្នកស្ម័គ្រចិត្តក្រៅប្រទេស, គំរោងការគ្រប់គ្រងធនធានធម្មជាតិតំបន់ឆ្នេរនិងគំរោងការគ្រប់គ្រងធនធានជលផល។ ១០០ទំព័រ។

សៀវភៅនេះបានកែសំរួលតាមរយៈការជួយឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ, កម្មវិធីសំរបសំរួលមូលនិធិកិរិតតូចរបស់បរិស្ថានពិភពលោក, គំរោង (UNDP GEF-SGP) លេខBC-0037-19.X1.96.L/V, ភ្នាក់ងារសហរដ្ឋអាមេរិចសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ក្រោមកិច្ចសន្យាលេខAID-492-0444-C-00-6028-00 បានជួយគាំទ្រគំរោងរបស់នាយកដ្ឋាន បរិស្ថាននិងគ្រប់គ្រងធនធានតំបន់ឆ្នេរ មហាវិទ្យាល័យប្រទេសហ្វីលីពីន មជ្ឈមណ្ឌលសិក្សាសំរាប់ការអភិវឌ្ឍន៍ចំរុះ (UP-MSI) និងគំរោងការគ្រប់គ្រងធនធានជលផលដែលបានអនុវឌ្ឍន៍អាស៊ី (ADB), ធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន។នេះជាទស្សនៈរបស់អ្នកនិពន្ធដែលបានបង្ហាញឡើង និងដោយមិនចាំបាច់បញ្ចោក់ឡើងវិញនូវទស្សនៈរបស់គំរោង''UNDP GEF-SGP,USAID,UP-MSI or FRMP.

អ្នកផលិត:

អ្នកត្រួតពិនិត្យ: Jordan P.Santos

តុបតែងរូបភាព: JordanP.Santos, Paulin A.Gaite, Ma.Fritzie D.Uychiaoco, AdreJonUychiaoco

ចំលងបោះពុម្ព: លោកទីឌីសូន (Letty Dizon)



A.J. Uychiaoco. University og the Philippines Marine Science Institute, Diliman, Quezon City 1101. Tel. (632) 920-5301 ext. 7426; Fax (632) 924-6778; Email: auychiaoco@yahoo.com

M. T. dela Cruz. Guiuan Development Foundation, Inc. and University of the Philippines, Visayas 117 P. Zamora St., Tacloban City, Leyte 6500 Tel. (6353)411-4405; Email: margarita.de la cruz@up.edu.ph

S. J. Green. Coastal Resource Management Project. Bohol Environment Management Office, Capitol Site, Tagbilaran City, Bohol 6300. Tel. (6338) 411-4405; Email: bosicadd@mozcom.com

UNDP Global Environment Facility-Small Grants Program
Rm 210, NEDA sa Makati Bldg., 106 Amorsolo St., Legaspi Village, Makati, Metro Malina, Philippines.
Tel. (632) 892-0611 ext. 241; Fax: (632) 813-0593; Website: www.psdn.org.ph/gef/sgp-home.htm;
Email: angie.cunanan@undp.org

Coastal Resource Management Project
5/F Cebu international Finance Corporation Towers, J. Luna St. corner J.L. Briones Ave., North Reclamation Areas, Cebu City 6000
Tel. (6332) 232-1821 to 22, 412-0487 to 89; Fax: (6332) 232-1825; Hotline 1-800-1888-1823; Website: www.oneocean.org; Email: crmp@oneocean.org or crmhot@mozcom.com



CRMP Document No. 11-CRM/2001
UP-MSI Contribution No. 308

ISBN No. 971-92290-0-4

# តើមានអ្វីនៅខាងក្នុង



| ជំពូក | ចំណងជើង | ទំព័រ |
|---|---|---|


| | ប្រវត្តិ និង សេចក្ដីថ្លែងអំណរគុណ | iv |
|---|---|---|
| | អារម្ភកថា | vi |
| | **សេចក្ដីផ្ដើម** | |
| ១. | តើផ្កាថ្មគឺជាអ្វី? | ១ |
| ២. | តើការត្រួតពិនិត្យ គឺជាអ្វី? | ៥ |
| ៣. | ហេតុអ្វីចាំបាច់ត្រួតពិនិត្យផ្កាថ្ម? | ៨ |
| ៤. | ការគ្រោងឡើងនូវផែនការសំរាប់ត្រួតពិនិត្យផ្កាថ្មមួយ? | ១១ |
| | **ការតាមដានត្រួតពិនិត្យ** | |
| ៥. | ការអង្កេត ពពួកផ្កាថ្ម និង ស្លែ | ១៩ |
| ៥. | វិធីសាស្ត្រម៉ុងតាថូ | ១៩ |
| ៥ខ. | ការអង្កេតដោយប្រើបំពង់ខ្យល់ | ២៦ |
| ៥គ. | វិធីសាស្ត្រសំរាប់ចំនុចនៅតំបន់ខ្សែម៉ែត្រ | ៣១ |
| ៥. | ការអង្កេតពពួកត្រីនៅក្នុងតំបន់ផ្កាថ្ម | ៣៩ |
| ៦. | ការអង្កេតទៅលើសត្វឥតឆ្អឹងកងខ្នង | ៥១ |
| ៧. | ការអង្កេតទៅលើការរំខានដោយសកម្មភាពរបស់មនុស្ស និងកត្តាធម្មជាតិ | ៥៣ |
| ៨. | ការតាមដាននិងត្រួតពិនិត្យ ផលនេសាទ | ៥៧ |
| | **ការវាយតំលៃ** | |
| ៩. | ការបកស្រាយទៅលើលទ្ធផលនៃការអង្កេត | ៦៧ |
| ១០. | ការវាយតំលៃ និង និងការដោះស្រាយ | ៧៣ |
| | **ឯកសារយោង** | ៧៩ |
| | **តារាងឧបសម្ព័ន្ធ** | |
| ១. | ប្រភពឯកសារ សំរាប់ ការបណ្ដុះបណ្ដាលជំនាញតាមដាន និង ត្រួតពិនិត្យផ្កាថ្ម | ៨០ |
| ២. | ទំរង់ទិន្នន័យគំរូប្រើសំរាប់គោលការណ៍ណែនាំ | ៩២ |

# ប្រវត្តិ និង សេចក្តីថ្លែងអំណរគុណ

ប្រព័ន្ធអង្កេតផ្កាថ្មដូចជារីហ្វឆែក (Reef Check) ដោយលោកហុតសុន (Hodgson, ១៩៩៩) វិធីសាស្ត្រអង្កេតបរិបំរួលសំរាប់អ្នកស្ម័គ្រចិត្តតាមដានមើលផែនទី និង គំរោងអភិរក្សដោយលោកវ៉ាយ (White *et all.*, ២000) និង ប្រព័ន្ធ ReefBases Aquanaut system) ដោយលោក ម៉ាក់ម៉ាណុស (McManus *et all*, ១៩៩៧) គឺសំរាប់អ្នកស្គូបា (SCUBA Divers) ដែលមានបំណងតាមដាន ត្រួតពិនិត្យផ្កាថ្មជាមួយ និងផលប្រយោជន៍នៃការចាប់ផ្តើមវគ្គបណ្តុះបណ្តាល ។ មានវិធីសាស្ត្រផ្សេងៗទៀត ដូចជាប្រព័ន្ធវិធីសាស្ត្រតាមដានត្រួតពិនិត្យផ្កាថ្មពិភពលោក (Global Coral Reef Monitoring Network System) ដោយលោកអង់គ្លេស (English *et all*, ១៩៩៧) សំរាប់អ្នកវិទ្យាសាស្ត្រផ្កាថ្មដែលចង់ធ្វើការតាមដានត្រួតពិនិត្យផ្កាថ្មលំអិត ។ ដោយសារកង្វះអ្នកស្ម័គ្រចិត្តស្គូបា និង អ្នកវិទ្យាសាស្ត្រផ្កាថ្មធ្វើការតាមដានគ្រប់ទីកន្លែងនៅក្នុងពិភពលោក ឬ ក៏ដូចផ្កាថ្មនៅប្រទេសហ្វីលីពីន ។ វិធីសាស្ត្រងាយៗសំរាប់អ្នកមិនចេះស្គូបា ត្រូវបានគេអភិវឌ្ឍន៍កែច្នៃពីវិធីសាស្ត្រខាងលើ ។ សៀវភៅណែនាំងាយៗនេះធ្វើសំរាប់ណែនាំ ដល់សហគមន៍ និងអ្នកស្រាវជ្រាវមូលដ្ឋានដែលធ្វើការក្នុងគំរោងតាមដានត្រួតពិនិត្យក្នុងតំលៃនៃការចាយវាយតិច បច្ចេកទេសស្រាវជ្រាវតិច និងអាចវាយតំលៃពីផលប៉ះពាល់សំរាប់ការខំប្រឹងប្រែងគ្រប់គ្រងតំបន់ ឆ្នេររបស់ពួកគាត់ ។

សៀវភៅណែនាំនេះកើតចេញពីការខំប្រឹងផ្ទាល់របស់លោកដែលាគ្រូស (M.T. Dela Cruz) ក្នុងឆ្នាំ ១៩៩៥ នៅខាងកើតសាមា (Eastern Samar) និងលោកគ្រីន (S.J Green) ឆ្នាំ ១៩៩៦ នៅបូហុល (Bohol) ដើម្បីណែនាំសហគមន៍នេសាទមូលដ្ឋានក្នុងវគ្គបណ្តុះបណ្តាលតាមដានត្រួតពិនិត្យក្នុងទឹកសំរាប់បរិស្ថានសមុទ្រ និង ការពារ ។ លោក ដែលាគ្រូស (ដែលធ្វើការនៅវិទ្យាល័យវិសាយាស ប្រទេសហ្វីលីពីន) បានស្នើនូវដំណោះស្រាយមួយសំរាប់នាយកដ្ឋានអេកូឡូស៊ី និង ការវិវត្ត (Evolution) ទៅមហាវិទ្យាល័យសហរដ្ឋអាមេរិចទីក្រុងញូយក នៅឯ Stony Brook ដើម្បីស្រាវជ្រាវអំពីផលប៉ះពាល់ដល់ដែនសមុទ្របំរុងទុកក្នុងការស្តារឡើងវិញនូវប្រព័ន្ធជីវៈផ្កាថ្មចំរុះ ។ ដោយមានការជួយជ្រោមជ្រែងពីលោក មីលីតាន (M.C.GMilitante) ។ លោកគ្រីន (S.J Green) គឺជាអ្នកស្ម័គ្រចិត្តមកពីអង់គ្លេស (Voluntary Service Overseas, VSO program) ។ ក្នុងឆ្នាំ ១៩៩៦ លោក អ៊ូអ៊ីឈីអាកូ (A.J. Uychiaoco) ធ្វើការនៅវិទ្យាស្ថានស្រាវជ្រាវសមុទ្រនៅមហាវិទ្យាល័យប្រទេសហ្វីលីពីនបានស្នើ ។

លោកដែលាគ្រូស និង គ្រីនបានជួបគ្នា និង រៀបចំផែនការសហប្រតិបត្តិការតាមរយៈសកម្មភាពផ្សេងៗរបស់ប្រព័ន្ធពតិមានអំពីផ្កាថ្មនៅប្រទេសហ្វីលីពីន (Philippine Coral Reef Information Network,Philreefs) នាចុងឆ្នាំ ១៨៨៦ ។ មូលនិធិត្រូវបានផ្តល់ដោយមហាវិទ្យាល័យនៃមជ្ឈមណ្ឌលកណ្តាលហ្វីលីពីនសំរាប់ការសិក្សាចំរុះនិងអភិវឌ្ឍន៍នៅពេលចាប់ផ្តើមការងារ ។ ក្រោយមកទៀត គំរោងគ្រប់គ្រងធនធានធម្មជាតិ និង តំបន់ឆ្នេររបស់ភ្នាក់ងារសហរដ្ឋអាមេរិចសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ និងកម្មវិធីសំរបសំរួលមូលធនកិរិតតូចពិភពលោករបស់អង្គការសហប្រជាជាតិ (United Nations Developement Programme Project Global Envioronmemt Facillity-Small Grants Programme) បានចូលរួមក្នុងឆ្នាំ ១៩៩៧ ។ លើសពីនេះទៅទៀត មូលនិធិត្រូវបានបន្ថែមដោយអង្គការ UP.MSI មូលនិធិអភិវឌ្ឍន៍Guiuan និង មូលនិធិចំរុះBohol ។ តាមរយៈការប្រឹងប្រែងចូលរួមទាំងនេះ វិធីសាស្ត្រ ដែលបានពិពណ៌នាពីជំពូកទី ១ រហូតដល់ជំពូកទី ៩ ត្រូវបានបំពេញសាកល្បងដោយក្រុមការងារផ្សេងៗដោយអ្នកមិនចេះ ស្គូបា (non SCUBA divers) នៃអ្នកស្ម័គ្រចិត្តនៅតាមសហគមន៍មូលដ្ឋាន ។

ការសាកល្បងនៅកន្លែងស្រាវជ្រាវ និង ការលើកកំពស់នៃវិធីសាស្ត្រនេះ គឺជាលទ្ធផលនៃការចូលរួម និង បំពេញបន្ថែមដោយមនុស្ស និងក្រុមជាច្រើននៅតាមទីកន្លែងជាច្រើនដូចជា: Sarmars សកម្មភាពតាមដានត្រួតពិនិត្យដែលបានសរសេរបញ្ចូលនៅក្នុងសេចក្តីណែនាំនេះ ដោយលោក អូអ៊ីឈីអាអូកូ, គ្រីន. អារសេអូ, ហ្គាយនិង ទីរីស ។ លើសពីនេះទៅទៀតអ្នកសរសេរត្រូវបានជួយសំរួលដោយលោកម៉ាប្រ៊ីកហ្ស៊ីសដី. អូអ៊ី ឈីអាអូកូ (Ma.Fritzie D.Uychiaoco) អ្នកដែលបានទទួលខុសត្រូវក្នុងការរំលឹកសង្ខេប កែតំរូវ និង ត្រួតពិនិត្យលំអិតសៀវភៅណែនាំនេះមានលោកគ្រីន (S.J.Green) , វ៉ាយ (A.T.White) , កៃជីនគុលម៉ាន (Kai-Jens Kuhlmann) , អាលីណូ (P.M.Alico) , លោកអូអ៊ីឈីអាកូ (A.J Uychiaoco) , គ្រីគ័រហុកសុន. (Gregor Hodgson) , ម៉ូរ៉ាល់ (C.Morales) , រូស (M.Ross) , អាវលីន (Arlene) , ប្រូក (Brook,VSO) , ម៉ាអែវណាយទីងហ្គាល់ (Maeve Nightinggale,VSO) , ការ៉េនវីឌ្លី (Karen Vidle) , ម៉ាកវៃលជីម៉ាត (Maike Waltermath) និង អ្នកចូលរួមផ្សេងៗទៀតរបស់VSO ទទួលខុសត្រូវសិក្ខាកាមអំពីតំបន់សមុទ្រការពារ និង អ្នកឧបត្ថម្ភសិក្ខាសាលា MPA របស់ UP-MSI ក្នុងខែឧ្ស ឆ្នាំ១៩៩៧។ អ្នកចូលរួមក្នុងសិក្ខាសាលាបានចូលរួមបង្កើតសៀវភៅនេះអំពីវិធីសាស្ត្រចូលរួមសំរាប់ការគ្រប់គ្រងធនធានធម្មជាតិតំបន់ឆ្នេរដោយផ្អែកលើសហគមន៍ដែលធ្វើឡើងនាខែកញ្ញាឆ្នាំ១៩៩៧រៀបចំឡើងដោយវិទ្យាស្ថានអន្តរជាតិសំរាប់ការស្ថាបនាតំបន់ជនបទឡើងវិញ និង បានជួយផងដែរនូវការស្វែងរកការសរសេរ និង វិធីសាស្ត្រតាមដានត្រួតពិនិត្យ ។

ចុងបញ្ចប់ការរំលឹកឡើងវិញអំពីការចូលរួមនិងជំរុញយ៉ាងកក់ក្តៅក្នុងការអភិវឌ្ឍន៍បទពិសោធន៍ គ្រឹះនិង ការសរសេរសេចក្តីណែនាំអំពីការតាមដានត្រួតពិនិត្យផ្កាថ្ម, អ្នកនិពន្ធបានសរុបការទទួលខុសត្រូវនៃលទ្ធផល និងកំហុសខ្លះៗ ឬ ការកែតំរូវអ្វីដែលនៅសេសសល់ ។

# អារម្ភកថា

វិធីសាស្ត្រណែនាំក្នុងសៀវភៅណែនាំ គឺផ្តោតសំខាន់ទៅលើ ពពួកផ្កាថ្ម ពីព្រោះ ផ្កាថ្មគឺងាយនិងទទួលនូវការប៉ះពាល់ ជាង ព្រៃកោងកាង និង ស្មៅសមុទ្រ ។ ដោយសារវាមានផលិតផលខស់ក្នុងធម្មជាតិ និងមានសោភ័នភាពទាក់ទាញ ជាញឹកញាប់ ផ្កាថ្មគឺជាមជមណ្ឌលកណ្តាលក្នុងតំបន់សមុទ្រដែលត្រូវការពារ ក៏ដូចជាតំបន់ដែលទាក់ទាញលបំផុតផង ដែរ ។ ព្រៃកោងកាងក៏មានអត្ថិភាពសំខាន់ផងដែរសំរាប់ការគ្រប់គ្រង និងសំខាន់ណាស់សំរាប់រូបសាស្ត្រការពារផ្កាថ្មដ៏ សំខាន់ពីកំណាកកករ និងព្យុះ ប៉ុន្តែនិងមាននិយាយលំអិតនៅក្នុងសៀវភៅផ្សេង ។យើងត្រូវការការពារផ្កាថ្មយើងអោយបានទូលំទូលាយ ធ្វើអោយយើងអាចបន្តបានផលប្រយោជន៏យ៉ាងច្រើនពីវា ។ យើងមិនត្រូវមានការភ័ន្តច្រឡំក្នុងការប្រែប្រួលផ្កាថ្មទេ ព្រោះវាបណ្តាលអោយយើងអាចប្រាប់ពីការប្រើប្រាស់បច្ចុប្បន្ននិង ការងារ គ្រប់គ្រង ថាវាមាននិរន្តភាព និងតើអាចបង្កើនការគ្រប់គ្រង ។

យើងត្រូវតែទទួលខុសត្រូវផងដែរក្នុងការវាយតំលៃអោយបានត្រឹមត្រូវនូវកត្តាផ្សេងៗក្នុងការប្រែប្រួលពពួកផ្កាថ្ម ។ សៀវភៅណែនាំនេះពិពណ៌នាអំពីវិធីសាស្ត្រផ្សេងៗ ដែលសហគមន៏មូលដ្ឋានអ្នកស្ម័គ្រចិត្តនិងស្ថាប័នអ្នកពាក់ព័ន្ធផ្សេងៗអាចប្រើសំរាប់តាមដានត្រួតពិនិត្យនិងវាយតំលៃបំរែបំរួលពពួកផ្កាថ្មរបស់គេសំរាប់លើកកំពស់ក្នុងការគ្រប់គ្រង ។ សេចក្តីណែនាំទាំងនេះគ្រាន់តែផ្តល់ការណែនាំ ដល់សហគមន៏ក្រោយពេលដែលគាត់មានការយល់ដឹង ពីមូលដ្ឋានគ្រឹះរបស់ការការយល់ដឹងខាងផ្នែកបរិស្ថានយល់ច្បាស់អំពីតំលៃរបលស់ផ្កាថ្ម និងមានបំណងបង្ហាញនូវការសន្យាក្នុងការថែរក្សាពពួកផ្កាថ្មនៅក្នុង តំបន់របស់គាត់ (ឧ.មានការបង្កើតជាទីជំរកបំរុងទុក) ។

សៀវភៅនេះណែនាំនិងពិពណ៌នាអំពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងការវាយតំលៃពពួកផ្កាថ្មដែលរៀបឡើង សំរាប់សហគមន៏មូលដ្ឋានតំបន់ឆ្នេរ ដែលមិនបានរៀបអំពីស្កូបា ។ ផ្ទុយទៅវិញអ្នកដែលមានបំណងប្រើវិធីសាស្ត្រតាម ដានត្រួត ពិនិត្យនេះត្រូវតែពូកែខាងស្នូកខែល (មុជទឹកភាក់ៗ) ។ សៀវភៅណែនាំនេះចង្អុលបង្ហាញអំពីសារៈសំខាន់ក្នុងការតាមដាន ត្រួតពិនិត្យផ្កាថ្ម, ដំណាក់ការក្នុងការប្រមូលទិន្នន័យវិភាគទំនោរនៃការប្រែប្រួល និងចេះជ្រើសរើសដំណោះស្រាយដោយផ្អែកលើលទ្ធផលនៃការអង្កេត ។ វិធីសាស្ត្រពិពណ៌នាងាយៗនេះគឺមិនចំលែកឬខុសពីទំរង់ដើម ។ វាត្រូវបានបង្កើតបង្កើតឡើងមកពីការកែច្នៃវិធីសាស្ត្រផ្សេងៗសំរាប់អ្នកស្ម័គ្រចិត្តស្កូបា និងអ្នកវិទ្យាសាស្ត្រផ្កាថ (សូមមើលក្នុងប្រវត្តិ និងសេចក្តីថ្លែងអំណរ គុណ) ប្រព័ន្ធវិធីសាស្ត្រនេះគឺកែច្នៃឡើងជាពិសេសក្នុងការប្រមូលទិន្នន័យដែលអាចប្រដូចគ្នាបានទៅនឹងការ ប្រមូលទិន្នន័យ ក្នុងវិធីសាស្ត្រផ្សេងៗទៀត ។ ធីសាស្ត្រនេះនឹងផ្តល់ក្តីសង្ឃឹមថាជំនាញក្នុងការតាមដានត្រួតពិនិត្យនិងចំណេះដឹងពីការតាមដានត្រួតពិនិត្យនឹងជួយផ្តល់អំណាចដល់សហគមន៏មូលដ្ឋានក្នុងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព ។

សៀវភៅណែនេះមានបំណងជួយទាំងអ្នកអភិវឌ្ឍន៏ទាំងសមាជិកតាមដានត្រួតពិនិត្យផ្កាថ្ម ។ មានកំណត់សំគាល់សំរាប់គ្រូបង្រៀននៅគ្រប់ជំពូក ។ វាបានបញ្ជាក់ដល់គ្រូបង្រៀនក្នុងការបង្រៀន មានលំហាត់អនុវត្តន៏ក្នុងការតាមដានត្រួតពិនិត្យ និងវាយតំលៃផ្កាថ្ម ។ អ្នកបង្រៀនត្រូវលើកកំពស់
សិក្ខាកាមក្នុងការពិភាក្សាយ៉ាងទូលំទូលាយអំពីការអង្កេតវិធីសាស្ត្រ និងគំនិតផ្សេងៗក្នុងមូលដ្ឋានក៏ដូចជាលក្ខណបុគ្គល ។សិក្ខាកាមនិមួយៗគួរតែមានឯកសារថតចំលងក្នុងសៀវភៅនេះសំរាប់ប្រើ និងកត់ត្រាទិន្នន័យ ។សិក្ខាកាមទាំងអស់ត្រូវបាន លើកកំពស់សមត្ថភាពដែលនឹងអាចក្លាយជាគ្រូបង្រៀន ។

ការណែនាំអំពីត្រី និងពពួកសត្វឥតឆ្អឹងកងគឺសំខាន់ណាស់ ។ ក្រុមតាមដានត្រួតពិនិត្យនិមួយៗគួរមានសៀវភៅ ថតចំលងមួយឬច្រើនអំពីជីវិតរស់នៅរបស់ផ្កាថ្ម ។ ហើយក៏គួរតែមានផងដែរនូវស្រោមមុខ និងបំពង់ខ្យល់ពីរកំផ្លែ និង ក្តារឆ្នួនសំរាប់សរសេរក្នុងទឹក៤កំផ្លែសំរាបម្នាក់ៗ ។ ប្រដាប់កំនត់ទីតាំង (GSP) ក៏មានតួនាទីសំខាន់ណាស់សំរាប់ កំណត់ទីតាំងអង្កេត ។

សៀវភៅណែនេះប្រើសំរាប់ចុះអនុវត្តន៏ផ្ទាល់ ។ អានសាកល្បងហើយគិតប្រើវា និងកែច្នៃវាសំរាប់ការតាមដាន ត្រួតពិនិត្យពពួកផ្កាថ្មសំរាប់ការគ្រប់គ្រង ។

# តើផ្កាថ្មគឺជាអ្វី ?

# 1

ផ្កាថ្មរឹងគឺជាក្រុមសត្វតូចៗ (រូបាសិលាប្រាណ) ដែលខ្លួនីមួយៗមានរាងបំពង់ និងមាត់ហ៊ុំព័ទ្ធទៅដោយប្រម៉ោយជាច្រើននៅខាងចុង។ ក្រុមសត្វទាំងនោះពួនបានជាបណ្តុះគ្រោងឆ្អឹងជាតិកំបោររាងដូចពែងព័ទ្ធជុំវិញខ្លួនវា។ (ចំណែកឯផ្កាថ្មទន់មានគ្រោងឆ្អឹង ដែលផ្ដុំដោយសរីរាង្គតូចៗជាច្រើនបង្កើតបានគ្រោងឆ្អឹងនេះ ហើយដែលធ្វើអោយគ្រោងឆ្អឹងផ្កាថ្មទន់មិនរឹងទេ។





ក្រុមសត្វនិមួយៗ រីកលូតលាស់ និងបំបែកខ្លួនជាបន្តបន្ទាប់ បង្កើតបានបណ្តុំមួយ ។ ស្លែដែលមានជាតិកំបោរជាអ្នកផ្សាភ្ជាប់បន្តុំទាំងនេះ ហើយបង្កើតបានជាគ្រោងរឹងដែល ហៅថាផ្កាថ្ម។

ផ្កាថ្មមានដុះលូតលាស់នៅតែតំបន់ត្រូពិចដែលមានអាកាសធាតុក្តៅមធ្យម។ ផ្កាថ្មអាចស្លាប់ដោយសារកករកំទេចកំទីគ្របដណ្តប់ខ្លួនវា ហេតុដូច្នេះហើយវាត្រូវការចរន្តទឹកហូរលាងសំអាតខ្លួនវាជាប្រចាំ។ លើសនេះទៀតពពួកស្លែ ដែលរស់នៅជាមួយផ្កាថ្មវាក៏ត្រូវការពន្លឺថ្ងៃដើម្បីធ្វើរស្មីសំយោគ ហើយវាក៏បានជំរុញអោយផ្កាថ្ម រីកលូតលាស់លឿនផងដែរ។







សហគមន៍រុក្ខជាតិក្នុងទឹក ស្លែ សត្វ និង ភាវរស់ផ្សេងទៀតមានអន្តរអំពើទៅវិញទៅមកខាងក្នុង និង ជុំវិញតំបន់ផ្កាថ្ម។




រុក្ខជាតិទឹក សត្វ និង ពពួកភាវរស់ស៊ីកំទិចកំទីមានទំនាក់ទំនងគ្នាពីមួយទៅមួយដោយ "ខ្សែសង្វាក់" នៃការស៊ីគ្នាទៅវិញទៅមក។

សត្វស៊ីរុក្ខជាតិ និង/ឬ

សត្វផ្សេងៗទៀតជាអាហារ





**សត្វដែលស៊ីសត្វ និងរុក្ខជាតិជាអាហារ**

ត្រី ឧ. ត្រីតុកកែ

សត្វឥតឆ្អឹងកង ឧ. ខ្យង ដង្កូវ

**សត្វស៊ីរុក្ខជាតិជាអាហារ**

ត្រី ឧ. ត្រីសេក

ត្រីទន្សាយ

សត្វឥតឆ្អឹងកង

ឧ. កាំប្រម៉ាសមុទ្រ

ក្តាម



...ស្លែ ស្មៅសមុទ្រ

**សត្វស៊ីកំទេចកំទីជាអាហារ**

រុក្ខជាតិ និង វារិជាតប្រើប្រាស់ពន្លឺព្រះអាទិត្យ

ឧស្ម័ន និង សារធាតុបំប៉នក្នុងអាហារ ។

សត្វឥតឆ្អឹងកង

ឧ. ឈើងសមុទ្រ

គ្រំ ស្លង់

សត្វដែលស៊ីកំទេចកំទីជាអាហារ បំបែក សារពាង្គកាយស្លាប់របស់រុក្ខជាតិ សត្វ និង ភាវរស់ផ្សេងទៀត ដើម្បីបង្កើតជាអាហារ ។

**ស្រទាប់បាតសមុទ្រ ទន់**

ខ្សាច់ និង ភក់





## ជំហានសំរាប់គ្រូក្នុងជំពូក ១ ដល់ ៤

**ចំនុចគន្លឹះ**

១- ការត្រួតពិនិត្យ និង វាយតំលៃ គឺមានសារសំខាន់សំរាប់ការគ្រប់គ្រង និង ដើម្បីបង្ហាញអោយឃើញនូវការផ្លាស់ប្តូរនៃលក្ខណៈជីវ-រូបសាស្ត្រ និង ស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចសង្គមក្នុងតំបន់ដែលគ្រប់គ្រងនោះ ។

២- ការអង្កេតត្រូវធ្វើឡើងនៅក្នុងទីកន្លែងកំសាន្ត និង ពេលវេលាកំណត់មួយចំនួន ។

៣- ការអង្កេតពីសន្ទស្សន៍ទាំងឡាយដែលបង្ហាញនូវអ្វីដែលអ្នកចង់ដឹង ។

៤- ផែនការត្រួតពិនិត្យត្រូវតែបង្កើតឡើងអោយបានច្បាស់លាស់ ។

ដូច្នេះទើបមាននិយមន័យជាច្រើននៃពាក្យគ្រប់គ្រង ។ និយមន័យដែលជាមូលដ្ឋានគ្រឹះនៃពាក្យយុទ្ធសាស្ត្រនៃការគ្រប់គ្រងត្រូវបានកែលំអជា បន្តបន្ទាប់ថាជាការស្វែងយល់នូវការអភិវឌ្ឍន៍នៃប្រព័ន្ធគ្រប់គ្រង ។

វាមានសំខាន់ណាស់ដែលសន្ទស្សន៍ផ្សេងៗ ដែលអ្នកសំរេចចិត្តជ្រើសរើសយកមកត្រួតពិនិត្យមានទំនាក់ទំនងទៅនឹងអ្វីដែលសហគមន៍ ចង់ដឹង ។ បើសិនការប្រើប្រាស់ធនធាននាពេលថ្មីៗនេះមាននិរន្តរភាពក្រោមយុទ្ធសាស្ត្រគ្រប់គ្រងក្នុងពេលបច្ចុប្បន្នសន្ទស្សន៍ដែលបានត្រួតពិនិត្យ ពិតជានៅថេរ ឬប្រែប្រួលតាមទិសដៅកំណត់ មួយ (ឧទាហរណ៍ ស្ថិតិផលនេសាទត្រីមានស្ថេរភាព រឺ កើនឡើង) ។ បើសិនជាអ្នកកំពុងវាយ តំលៃការគ្រប់គ្រងសន្ទស្សន៍ដែលរើសយកមកត្រួតពិនិត្យត្រូវតែឆ្លើយតបទៅនឹងប្រសិទ្ធិភាពនៃការគ្រប់គ្រង ។

វិធីសាស្ត្រនៃការត្រួតពិនិត្យផ្ទាល់ដែលបានអធិប្បាយនេះ ជាទូទៅធ្វើឡើងសំរាប់យកប្រភេទទិន្នន័យសាមញ្ញៗដែលអាចបង្ហាញពី មូលហេតុនៃបំរែបំរួលបាន ។ ទិន្នន័យលំអិតថែមទៀតអាចបង្ហាញដោយសន្ទស្សន៍ដែលត្រូវជ្រើសរើសតាមការចាប់អារម្មណ៍ ។ តារាងនៅក្នុង ឧបសម្ព័ន្ធ បានបង្ហាញពីវិធីសាស្ត្រ ត្រួតពិនិត្យផ្សេងៗក្នុងការប្រមូលថែមទៀតនូវពត៌មានលំអិតក៏ដូចជាទំហំនៃពត៌មានលំអិត ។

បើសិនភាវរស់ដែលអ្នកធ្វើការសិក្សាអង្កេតមានលក្ខណៈ

- មានសកម្មភាពចរាចរណ៍ខ្លាំងក្លា អ្នកត្រូវតែយកគំរូច្រើនកន្លែង
- មានភាពសំបូរបែបខ្ពស់ អ្នកត្រូវការយកគំរូតិច
- របាយនៃភាវរស់ខុសគ្នាខ្លាំង អ្នកត្រូវការយកគំរូច្រើនថែមទៀត

**សំណួរសារឡើងវិញ**

១- តើគេប្រើអ្វីដើម្បីត្រួតពិនិត្យសំរាប់ការគ្រប់គ្រង?

២- តើផ្នែកអ្វីដែលសំខាន់ដែលយើងត្រួតពិនិត្យ?

៣- ហេតុអ្វីបានជាយើងត្រូវអង្កេតខាងក្រៅតំបន់ការពារផងដែរ? ហេតុអ្វីបានជាយើងអង្កេតក្នុងវេលាខុសគ្នា?

៤- ហេតុអ្វីបានជាយើងត្រូវតែធ្វើការអង្កេតជាច្រើនដងទៅតាមតំបន់ និង ពេលនីមួយៗ?

៥- តើតំណាងគំរូមានន័យដូចម្តេច?

តំណាងគំរូគឺជាផ្នែកមួយនៃគំរូដែលមានលក្ខណៈដូចគ្នាក្នុងតំបន់ទាំងមូល ។

# តើការត្រួតពិនិត្យ គឺជាអ្វី? ២

ការត្រួតពិនិត្យគឺជាការប្រើប្រាស់នូវវិធីសាស្ត្រគំរូបទដ្ឋានមួយដើម្បីអង្កេតទៅលើអ្វីមួយនៅទីកន្លែងមួយក្នុងកំឡុងពេលមួយកំណត់ ។




ពត៌មានដែលបានមកពីការត្រួតពិនិត្យតាមដាន វាដូចគ្នានឹងរូបភាពមួយ ។ ប្រៀបធៀបរូបភាពពីររបស់មនុស្សម្នាក់ថតនៅពេលវេលាខុសគ្នាអាចឃើញភាពខុសគ្នាប្រសិនបើមនុស្សនេះមានការផ្លាស់ប្តូរ ។ ដូចគ្នាដែរធ្វើការត្រួតពិនិត្យតាមដានគឺប្រមូលភស្តុតាងនៃការផ្លាស់ប្តូរ ឬប្រែប្រួល ។




យើងអាចធ្វើការសន្និដ្ឋានទៅលើនិន្នាការពីរូបភាពតូចៗគ្នា ។ និន្នាការនៃរូបភាពទាំងនោះអាចជួយអោយយើងទស្សទាយលើទិសដៅ និងល្បឿននៃការផ្លាស់ប្តូរទៅអនាគត ។

### ទៀនពិភាក្សា

ចូរសរសេរ ឬ គូរនៅលើទំព័រនេះពីការប្រែប្រួលសំខាន់ៗនៃតំបន់ផ្កាផ្ទះរបស់អ្នក ដែលអ្នកបានសង្កេតឃើញ តាំងពីរយៈពេល ១០ឆ្នាំមុន ។ សរសេរអំពីអ្វី ដែលអ្នកគិតថាជាហេតុដែលធ្វើអោយមានការផ្លាស់ប្តូរ និងអ្វីៗដែលអ្នកគិតថាគឺជាលិទ្ធផលនៃការប្រែប្រួលទាំងនោះ ។



| ឆ្នាំ | មូលហេតុ | ការផ្លាស់ប្តូរ | លទ្ធផលនៃការផ្លាស់ប្តូរ |
|---|---|---|---|
| | | | |

# ទិន្នន័យគំរូ

ឧទាហរណ៍

| ឆ្នាំ | មូលហេតុ | ការផ្លាស់ប្តូរ | ផលនៃការផ្លាស់ប្តូរ |
|---|---|---|---|
| ១៩៥០-១៩៧០ | ការនេសាទហួសកំរិត | ថយចុះពពួកត្រីដែលស៊ីសាច់ និងស៊ីចំរុះ និង ស៊ីរុក្ខជាតិជាអាហារ | មានពពួកស៊ីកាំប្រម៉ាសមុទ្រតិច និង មិនសូវមានពពួកសត្វ ដែលប្រជែងគ្នាស៊ីស្លែ |
| ១៩៥០-១៩៧០ | មានពពួកស៊ីកាំប្រម៉ាសមុទ្រ តិច និង មិនសូវមានពពួក សត្វដែលប្រជែងគ្នាស៊ីស្លែ | ពពួកកាំប្រម៉ាសមុទ្រកើនឡើង | ពពួកកាំប្រកាសមុទ្រ ច្រើនលើសលប់ |
| ១៩៨២-១៩៨៤ | ការទន្ទ្រានរបសវីរុសទៅ កាំប្រមាសមុទ្រ | ពពួកកាំប្រម៉ាសមុទ្រថយចុះ | ពពួកសត្វស៊ីរុក្ខជាតិដែលស៊ីស្លែ ជាអាហារមានចំនួនតិចតួច |
| ១៩៨៣-១៩៩០ | ពពួកសត្វស៊ីរុក្ខជាតិដែល ស៊ីស្លែជាអាហារមានចំនួន តិចតួច | ពពួកស្លែកើនឡើង (គ្របដណ្តប់ផ្កាថ្ម៤%-៩២%) | ពពួកស្លែរុំព័ទ្ធផ្កាថ្មទាំងស្រុង |
| ១៩៨៥-១៩៩០ | ពពួកស្លែរុំព័ទ្ធ ផ្កាថ្មទាំងស្រុង | ពពួកផ្កាថ្មថយចុះ(ភាគរយគ្រប ដណ្តប់តិចជាង៥២%) | |
| ១៩៨៧ ១៩៨៩ និង ១៩៩០ | ផ្កាថ្មងាប | ពពួកផ្កាថ្មថយចុះតទៅទៀត (រហូត ដល់ ៣%) | |

# ហេតុអ្វីចាំបាច់ត្រូវតែពិនិត្យផ្កាថ្ម?

## ៣









ប៉ុន្តែផ្កាថ្មបាននឹងកំពុងរងនូវការគំរាមកំហែងដោយវិធីសាស្ត្រនេសាទ បំផ្លាញ ការប្រមូលផលហួសកំរិត បង្ហូរទឹកកខ្វក់ ចាក់សំរាម កសិកម្ម គាស់យកផ្កាថ្ម ការបំពុលពីរោងចក្រឧស្សាហកម្ម ការខូចខាតដោយអ្នកទេសចរណ៍ សំណង់នៅតាមតំបន់ឆ្នេរ និងពិភពលោកឡើងកំដៅ ។

ដូច្នេះវាជាការសំខាន់ណាស់សំរាប់យើងក្នុងការជួយថែរក្សា និងគ្រប់គ្រងផ្កាថ្ម ។ យើងទាំងអស់គ្នាជួយថែរក្សា និងការពារបរិស្ថានតំបន់ឆ្នេររបស់យើងដោយបង្កើតតំបន់ការពារសមុទ្រ ( ដូចគ្នា នឹងដែនសមុទ្របំរុងទុក ឬដែនសមុទ្រដែលជាទីជំរក) ការឃាមល្បាតការអប់រំផ្សេងៗ ការធ្វើនិស្សរណកម្ម និង ការចាក់កាកសំណល់អោយបានសមស្រប ការដាំដើមឈើ និងកូនរុក្ខជាតិឡើងវិញ ។




អ្នកវិទ្យាសាស្ត្រផ្នែកផ្កាថ្ម និង អ្នកស្ម័គ្រចិត្តមុជទឹក SCUBA កំពុងតាមដានផ្កាថ្មនៅលើផែនដី។ នៅពេលនេះយើងបង្ហាញពីវិធីសាស្ត្រងាយៗសំរាប់អ្នកមុជទឹកដែលមិនចេះប្រើឧបករណ៍ SCUBA ដើម្បីអោយ សហគមន៍មូលដ្ឋាន និងមន្ត្រីជំនាញក្នុងស្រុកអាចមើលឃើញដោយខ្លួនឯង ថាតើមានអ្វីដែលកំពុងកើតមានឡើងទៅលើផ្កាថ្ម នៅបាតសមុទ្រ។

## ការរៀនពិភាក្សា

## សូមឆ្លើយទៅនឹងចំនុចដូចខាងក្រោមៈ



សូមសរសេរអំពីផ្កាថ្មអោយបាន ៣ ចំនុចដែលអ្នកយល់ថាមានសារៈសំ

1. ______________________________

2. ______________________________

3. ______________________________

## វដ្ដនៃការគ្រប់គ្រងដោយសកម្ម

សូមសរសេរបញ្ហាអាក្រក់ធំៗបីដែលកើតមានក្នុងបរិស្ថានតំបន់ឆ្នេររបស់អ្នក

1.
2.
3.

សូមសរសេរវិធីសាស្ត្របីយ៉ាងដែលអ្នកគិតថាអាចជួយដោះស្រាយបញ្ហាទាំងនេះបាន។

1.
2.
3.

សូមសរសេរលទ្ធផលបីយ៉ាងដែលចេញពីការខិតខំរបស់អ្នក

1.
2.
3.

សូមសរសេរវិធានការណ៍បីយ៉ាងដែលអ្នកគិតថាអាចជួយបង្កើនការគ្រប់គ្រងតំបន់ឆ្នេរបាន

1.
2.
3.

# ការគ្រោងឡើងនូវផែនការសំរាប់ត្រួតពិនិត្យតាមដានផ្កាថ្ម

# 4









ត្រូវអោយច្បាស់ក្នុងចិត្តនូវអ្វីដែលអ្នកចង់ដឹង ហើយ បន្ទាប់មកជ្រើសរើសយកបញ្ហាមួយចំនួនដើម្បីតាមដាន នៅកន្លែងមួយចំនួនទៅតាមរយៈពេលវេលា ។

ត្រូវតាមដាននូវអ្វីដែលអ្នកគិតថាអាចផ្លាស់ប្តូរដោយសារ ការគ្រប់គ្រងមិនបានល្អ ឬ ល្អនោះ

មាត្រដ្ឋាន : ⊖ អំពើថយចុះ

⊕ អំពើកើនឡើង

⊕ អាចជាអំពើកើនឡើង ឬ ថយចុះ ⊖

**អ្វីដែលចង់ដឹង ឬចាប់អារម្មណ៍**

**ប្រែប្រួលដោយសារតែ**

**ពពួកផ្កាថ្ម**



☆ ជំរកត្រី និង ជំរកសត្វផ្សេងៗ

☆ ទាក់ទាញភ្ញៀវទេសចរណ៍

☆ ការពារខ្យល់ព្យុះ

⊖ ការធ្វើនេសាទដោយបែបបំផ្លិចបំផ្លាញ

⊖ ល្បាប់ហូរចាក់

⊖ ការបំពុល

⊖ សំនង់តាមតំបន់ឆ្នេរ

⊖ ខ្យល់ព្យុះ

⊖ ការឡើងកំដៅនៅលើពិភពលោក

**ស្មៅ**



☆ អ្នកប្រជែងជាមួយផ្កាថ្ម

☆ ចំនីសំរាប់ត្រី និង ពពួកសត្វអត់ឆ្អឹងកងខ្នង

☆ ស្មៅខ្លះរស់នៅលើផ្កាថ្ម ហើយផលិតចំនីសំរាប់ផ្កាថ្ម និង សត្វអត់ឆ្អឹងកងខ្នងដទៃទៀត

⊕ ការបំពុល

⊕ ការនេសាទហួសកំរិត ⊖

⊕ ជំងឺរាតត្បាត ⊖

ស្មៅជាទូទៅដុះនៅលើពពួកផ្កាថ្ម ប៉ុន្តែក្នុងកាលទេសៈ ខ្លះវាធ្វើអោយស្មៅមានច្រើនហួស ឬក៏ខ្សត់ហួស ។

ពិនិត្យអង្កេតនៅក្នុងទីកន្លែង ខុស១គ្នាដូចជា:

នៅផ្នែកខាងក្នុង និង ផ្នែកខាងក្រៅនៃតំបន់គ្រប់គ្រង ឬ តំបន់ប្រើប្រាស់ (ឧទាហរណ៍:ផ្នែកខាងក្នុង និង ខាងក្រៅតំបន់ការពារសមុទ្រ) ព្យាយាមពិនិត្យអោយបានប្រាំកន្លែងនៅក្នុងតំបន់គ្រប់គ្រងនីមួយ១។

ពិនិត្យមុន និងរាល់ឆ្នាំបន្ទាប់ពីបង្កើតសកម្មភាពគ្រប់គ្រង។ អ្វីដែលមិនមានការផ្លាស់ប្តូរញឹកអាចតាមដានម្តងម្កាលបាន។

## នៅទីណា?

## នៅពេលណា?




ពីមុន និងរៀងរាល់ឆ្នាំបន្ទាប់ពីមានការគ្រប់គ្រង







ពីមុន និង រាល់ឆ្នាំបន្ទាប់ពីមានការគ្រប់គ្រង។ សុក្រិតបំផុតត្រូវធ្វើមួយរដូវម្តង



| **អ្វីដែលចង់ដឹង ឬចាប់អារម្មណ៍** | **ប្រែប្រួលដោយសារតែ** |
| --- | --- |

## ពពួកត្រី



☆ ជាម្ហូបអាហារ និងផ្តល់ប្រាក់ចំណូល

☆ ជះឥទ្ធិពលដល់ការប្រជែងគ្នារវាង ផ្កាថ្ម និងស្មៅ

+ តំបន់បំរុងទុក

− ការធ្វើនេសាទដោយបែបបំផ្លាញ និង នេសាទហួសកំរិត

+ ការផ្លាស់ប្តូរនៃពពួកផ្កាថ្ម −

+ ការត្រួតពិនិត្យ និងការអនុវត្តន៍ច្បាប់

## ពពួកសត្វអត់ឆ្អឹងកងខ្នង



☆ ជាម្ហូបអាហារ និងផ្តល់ប្រាក់ចំណូល

☆ មានឥទ្ធិពលដល់ការប្រជែងគ្នារវាង ផ្កាថ្ម និងរុក្ខជាតិ

+ តំបន់បំរុងទុក

+ ការភ្ញាស់កូនឡើងវិញ

− នេសាទហួសកំរិត

+ ជំងឺរាតត្បាត −

+ ការផ្លាស់ប្តូរនៃពពួកផ្កាថ្ម −

## ការនេសាទ



☆ ជាម្ហូបអាហារ និងផ្តល់ប្រាក់ចំណូល

+ តំបន់បំរុងទុក

+ ការផ្លាស់ប្តូរនៃពពួកត្រី និងពពួកសត្វឥតឆ្អឹងកងខ្នង −

+ ការត្រួតពិនិត្យ និងអនុវត្តន៍ច្បាប់

## សកម្មភាពផ្សេងៗរបស់បនុស្ស




☆ អំពើចំបងៗទៅលើការប្រែប្រួល

☆ យើងអាចធ្វើការផ្លាស់ប្តូរដោយផ្ទាល់

− ការបំផ្លាញព្រៃឈើនៅតំបន់ខាងលើ

+ ការសិក្សាអប់រំ

− ការអភិវឌ្ឍន៍តំបន់ឆ្នេរ

+ ច្បាប់ និងការអនុវត្តន៍ច្បាប់

## ការរំខានពីធម្មជាតិ



☆ អំពើចំបងៗទៅលើការប្រែប្រួល

☆ យើងមិនអាចធ្វើការផ្លាស់ប្តូរបានទេ

+ អាកាសធាតុពិភពលោក −

ឧទាហរណ៍បាតុភូត អេនីញូ

− មេរោគផ្សេងៗ

## ទីណា?

## ពេលណា?




យ៉ាងតិច

៥

កន្លែងនៅក្នុង

តំបន់គ្រប់គ្រងមួយ

គេត្រូវធ្វើការអង្កេតនៅតាមកន្លែងដដែល១




ពីមុន និងរាល់ឆ្នាំបន្ទាប់ពីការគ្រប់គ្រង ។ សុក្រិត្យបំផុត

មួយដងក្នុងមួយរដូវ




យ៉ាងតិច

៥

កន្លែងនៅក្នុង

តំបន់គ្រប់គ្រងមួយ

គេត្រូវធ្វើការអង្កេតនៅតាមកន្លែងដដែល១




ពីមុន និងរាល់ឆ្នាំបន្ទាប់ពីការគ្រប់គ្រង ។ សុក្រិតបំផុត

មួយដងក្នុងមួយរដូវ




នៅកន្លែងណាដែលអ្នកនេសាទធ្វើនេសាទ និង

នៅទីតាំងនេសាទនៃសមុទ្រក្នុង

## អ្នកណា



អ្នកនេសាទ១៥នាក់ ឬ ១០%នៃចំនួន

អ្នកនេសាទទាំងអស់




យកគំរូទៅតាមប្រភេទឧបករណ៍នេសាទផ្សេង១

ដែលប្រើប្រាស់ម្តងក្នុងរយៈពេលមួយឬពីរសប្តាហ៍




តំបន់សំខាន់១ទាំងមូល (ឧ. ទីក្រុង តំបន់ ខេត្ត)




យ៉ាងហោចយកគំរូម្តងក្នុងមួយឆ្នាំ ។ ជាការប្រសើរបើ

អាចធ្វើបានប្រចាំខែ ឬ ឆមាស




តំបន់សំខាន់១ទាំងមូល (ឧ. ទីក្រុង តំបន់ ខេត្ត)




ក្នុងមួយឆ្នាំម្តង


1
ជួបជាមួយសហគមន៍ និង ប្រជាជនដែល
ជាអ្នកសំខាន់ក្នុងការសំរេចចិត្ត
ត្រូវច្បាស់នូវអ្វីដែលអ្នកចង់ដឹង ។
2
កំណត់ថាតើវិធីសាស្ត្រត្រួតពិនិត្យតាមដាន
អាចជួយដោះស្រាយបញ្ហាបានដែរ ឬទេ
1997 =
1998 =
1999 = ?
3
ប្រើប្រាស់តារាងសំនួរទិន្នន័យ
TNT
TNT
ជ្រើសរើស ២ ឬ ៣ បញ្ហាដែលអាចប្រើជាសន្ទស្សន៍ ឬ
ជាចំលើយដ៏ផ្ទាល់នៃសំណួររបស់អ្នក ។
4
ពិភាក្សាថា តើអ្វីដែលបណ្តាលអោយមានការ
ប្រែប្រួលដល់តំរុយនៃសំនួររបស់អ្នក
APRIL
MARCH
MAP
ឯកភាពថា តើនៅទីណានិងញឹកញាប់ប៉ុណ្ណា
ក្នុងការត្រួតពិនត្យតាមដានសន្ទស្សន៍ទាំងនោះ
5
សំរេចថា តើវិធីសាស្ត្រត្រួតពិនិត្យណាមួយដែលក្រុម
នឹងត្រូវអនុវត្ត និងត្រូវធានាថាពួកគេនឹងយល់ពី
វិធីក្នុងការអនុវត្តនីវិធីសាស្ត្រទាំងនោះ ។
TNT
TNT
6
ធ្វើតារាងនូវអ្វីដែលចាំបាច់ និងចាត់តាំង
មនុស្សម្នាក់អោយទទួលខុសត្រូវដើម្បី
ត្រួតពិនិត្យលើសន្ទស្សន៍នីមួយៗ
question
indicators
person

ជា ឧទាហរណ៍ អ្នកអាចត្រួតពិនិត្យ ស្មៃ ត្រី

និងពពួកសត្វអត់ឆ្អឹងកងខ្នង នៅក្នុងនិងក្រៅតំបន់

ការពារសមុទ្ររបស់អ្នក







* ជំរៅទឹកដែលខ្សែម៉ែត្រនីមួយៗ ដាក់អោយស្របទៅនឹងឆ្នេរ : ៦ ម៉ែត្រ ( ជំរៅ ១៣ ម៉ែត្របើសិនជាមានអ្នកមុជទឹកដោយប្រើ SCUBA នោះ ។

ខ្សែម៉ែត្រក៏អាចដាក់តាមបណ្តោយជំរាលផងដែរ ។

**ត្រួតពិនិត្យរៀងរាល់ឆ្នាំ**

នៅរដូវប្រាំង

នៅរដូវខ្យល់មូ៉សុងឥសាន្ត

និង នៅរដូវខ្យល់មូ៉សុងនិរតី

ដូច្នេះការប្រែប្រួលពីរដូវមួយទៅរដូវមួយ អាចត្រូវបានគេកត់ត្រា

( ផ្កាថ្មគួរតែត្រួតពិនិត្យមួយដងក្នុងមួយឆ្នាំដោយសារវាមានការផ្លាស់ប្តូរយឺត)

# ឧ១ ទំរង់បែបបទគំរូ

ទំរាងទី ១. អាចត្រូវបានគេប្រើសំរាប់កំនត់ថា តើទិន្នន័យអ្វីដែលត្រូវប្រមូលនៅពេលធ្វើការត្រួតពិនិត្យ

**ទំរង់បែបបទគំរូ** — **តារាងទី១**

| សំណួរ រឿង ឬបញ្ហា | សន្ទស្សន៍ចាំបាច់ | តើអ្វីបណ្តាលអោយមានការផ្លាស់ប្តូរ | ______ នៅទីណា | តើត្រូវតាមដានត្រួតពិនិត្យនៅពេលណា | វិធីសាស្រ្តតាមដានត្រួតពិនិត្យ | សំភារៈចាំបាច់ | អ្នកអនុវត្តន៍ ការងារ | ពេលវេលា និងចំនួនថ្ងៃចាំបាច់ |
|---|---|---|---|---|---|---|---|---|
| ការនេសាទហួសកំរិត និងការលួចចាប់ត្រី នៅក្នុងតំបន់ការពារសមុទ្រ | ទំហំត្រី និង ភាពសំបូរ | ការប្រែប្រួល ចំនួនឧបករណ៍នេសាទ ការ វិនាសពីធម្មជាតិ ការប្រែប្រួល ការគ្រប់ដណ្តប់ របស់ផ្កាថ្ម ការអនុវត្តន៍វិធានការគ្រប់គ្រង | នៅខាងក្នុង និងក្រៅតំបន់ការពារ | រដូវខ្យល់មូសុងឥសានរដូវខ្យល់មូសុងនិរតី រដូវប្រាំង | ការអង្កេតដោយមើល និងរាប់ត្រី | ខ្សែ ៥០ម៉ែត្រមានចំនុចសំគាល់ត្រង់ ៥ ម៉ែត្រ វែនតា ហែលទឹក និងបំពង់ដកដង្ហើម ក្តារឆ្នួន ខ្មៅដៃ ទូក ប្រេង និង ក្រដាស តារាងសំរង់ទិន្នន័យ | ក្រុមតាមដានត្រួតពិនិត្យ តំបន់ការពារសមុទ្រ | ចុងអាទិត្យទី១ ខែមករា ចុងអាទិត្យទី១ខែឧសភា ចុង អាទិត្យទី ១ ខែកញ្ញា (២-៣ ថ្ងៃក្នុងមួយដង) |
| | ភាពសំបូរសត្វឥតឆ្អឹងកងខ្នង | ដូចខាងលើ | ដូចខាងលើ | ដូចខាងលើ | ការអង្កេតសត្វឥតឆ្អឹងកងខ្នង | ដូចខាងលើ | ដូចខាងលើ | ដូចខាងលើ |
| | ឧបករណ៍នេសាទ អត្រាផលចាប់ ក្នុងមួយឯកតា | ការកើនឡើងចំនួនឧបករណ៍នេសាទ ការអនុវត្តវិធានការគ្រប់គ្រងដូចជាការត្រួតពិនិត្យបទល្មើសនៅក្នុងតំបន់ការពារ ការអនុវត្តន៍ច្បាប់ | ភូមិទាំងមូល | យ៉ាងតិចមួយដង ក្នុងមួយសប្តាហ៍ | ការតាមដានត្រួតពិនិត្យផលចាប់ | ក្រដាសតារាងសំរង់ទិន្នន័យ ខ្មៅដៃសៀវភៅបន្ទុកតារាងរូបត្រីផែនទីតំបន់ជញ្ជីងថ្លឹង ម៉ាស៊ីនគិតលេខ | ក្រុមតាមដានត្រួតពិនិត្យ តំបន់ការពារ សមាគមន៍នារី | រាល់ថ្ងៃពុធប្រមូល និងកត់ត្រាបញ្ចូលក្នុងតារាងសំរង់ទិន្នន័យ នៅថ្ងៃសៅរ៍អាទិត្យទីបួននៃ ខែ បូកសរុបទិន្នន័យ |
| ការបំផ្លាញទីជំរកធម្មជាតិ | ការគ្របដណ្តប់របស់ផ្កាថ្ម | ការនេសាទដោយការបំផ្លិចបំផ្លាញ និងការ វិនាសពីធម្មជាតិ ដូចជាការត្រួតពិនិត្យបទល្មើសនៅក្នុងតំបន់ការពារ ការអនុវត្តន៍ច្បាប់ | នៅក្នុង និងក្រៅតំបន់ការពារសមុទ្រ | មួយឆ្នាំមួយដង | ម៉ុងតាថូ ការអង្កេតស្នូកខែល | ខ្សែ៥០ ម៉ែត្រមានចំនុចសំគាល់ តង់ ៥ម៉ែត្រវែនតាហែលទឹក និងបំពង់ដកដង្ហើម ក្តារឆ្នួន ខ្មៅដៃ ទូក ប្រេង និង ក្រដាសសំរង់ទិន្នន័យ នាឡិការ និង ត្រីវិស័យ GPS | ក្រុមតាមដានត្រួតពិនិត្យ តំបន់ការពារ | ចុងអាទិត្យទី១ ខែឧសភា (រយៈពេល១-២ ថ្ងៃ) |

# ការអង្កេតពពួកផ្កាថ្ម និង ស្មៅ

## វិធីសាស្ត្រម៉ុងតាថូ ការអង្កេតដោយស្នូកខែល និងចំនុចនៅខ្សែម៉ែត្រ

៥



### ១. វិធីសាស្ត្រម៉ុងតាថូ

**និយមន័យ**

វិធីសាស្ត្រម៉ុងតាថូ គឺជាការអង្កេតនៅក្នុងផ្ទៃទឹកដែលមានកំរិតថ្លាខ្ពស់ ដោយអ្នកមុជទឹកត្រូវបានអូស ដោយទូកតូចមួយ ។

**គោលបំនង**

វិធីសាស្ត្រម៉ុងតាថូ ត្រូវបានគេប្រើដើម្បីទទួលបាន នូវទិនន្ន័យទូទៅនៃប្រភេទផ្សេងៗ ចំនួនទីជំរក និងវត្ថុផ្សេៗដែលមាននៅក្នុងតំបន់មួយ ។ ពិតមានទាំងនេះត្រូវបានគេប្រើដូចជា:

- ✓ ជួយក្នុងការជ្រើសរើសទីកន្លែង និងចំនួនទីកន្លែងគំរូ សំរាប់ធ្វើការអង្កេតផ្ទាល់
- ✓ សំរាប់ធ្វើការប្រៀបធៀបជាមួយនឹងទស្សនៈអ្នកស្រុកអំពីតំបន់ឆ្នេរ
- ✓ ការបង្ហាញពីបំរែបំរួលដែលមានទ្រង់ទ្រាយធំ (ឧ. ដោយសារខ្យល់ព្យុះ ឬកំនក ល្បាប់ខ្លាំង)

**តំរូវការចាំបាច់**

១ ទូកតូច និងប្រេងឥន្ទនៈ

២ វ៉ែនតាមុជទឹក និង សំរាប់ដកដង្ហើម

៣ ក្តាបំណ្ណេតអូស

៤ ផែនទីតំបន់

៥ នាឡិកាដែលអាចបង្ហាញពីវិនាទី

៦ ខ្សែពួរប្រវែង ១៧ម (អង្កត់ផ្ចិតប្រហែល ១០មម មានចំនុចចំណាំក្នុងចន្លោះ៦ម និង ១២ ម នៅខាងចុង) ។

៧ ឧបករណ៍កំណត់ទីតាំង GPS ឬត្រីវិស័យ




១
ចំលងផែនទីតំបន់ដែលត្រូវធ្វើអង្កេតដាក់លើក្តារឆ្នួន
MAP
២
ធ្វើការកត់សំគាល់ទ្រង់ទ្រាយ (ទ្រង់ទ្រាយតំបន់នោះ និងព្រំប្រទល់) និង តំបន់ (ការប្រើប្រាស់ និងការ ការពារ) នៅលើផែនទី
MPA
៣
រៀបចំនិងកំណត់ទិសដៅក្នុងការអង្កេតតាមរបៀបមុងតាថូ (ជាទូទៅតាមជួរនៃបណ្តុំផ្កាថ្ម ឬ ស្របតាមជំរៅទឹកដែលបានជ្រើសរើស) នៅលើផែនទី
៤
ជ្រើសរើសពី ៣ ទៅ ៥ ផ្នែក (ឧ:ផ្កាថ្មរឹងរស់ ផ្កាថ្មងាប់ ផ្កាថ្មទន់ និង ដីខ្សាច់ ឬ ល្បាប់) ដើម្បីប៉ាន់ស្មាន
MANTA TOW DATA
Site Name:
Date
Time
TOW No.
HARD CORAL
SOFT CORAL
DEAD CORAL
៥
ភ្ជាប់ក្តាម៉ុងតាថូទៅនឹងទូកដោយប្រើខ្សែពួរ
៦
នៅពេលដែលអ្នកអង្កេតរៀបចំខ្លួនរួច និង អោយសញ្ញា "រួចរាល់" អូសអ្នកអង្កេតអោយស្របនិងពីលើតំបន់ផ្កាថ្ម តាមបណ្តោយតំបន់ដែលត្រូវអង្កេត ។

**៧** ក្នុងកំឡុងពេលអូសម្តង១ អ្នកអង្កេតត្រូវប៉ាន់ស្មានអំពីភាគរយគ្របដណ្តប់នៃផ្ទៃកនីមួយ១ ដែលបានជ្រើសរើសទុកក្នុងចំនុច ៤។ ក៏រិតភាគរយទាំងនោះមិនចាំបាច់បន្ថែមរហូតដល់ ១០០% នោះទេ។

(តំបន់ដែលបានអង្កេតអាចមើលឃើញទទឹងរហូតដល់ ១០ម អាស្រ័យដោយជំរៅ និង ភាពថ្លានៃទឹក)



នៅខណៈនោះដែរ អ្នកនៅលើទូកមួយនាក់មើលម៉ោងការពារសុវត្ថិភាពដល់អ្នកអង្កេតក្នុងទឹក ធ្វើសញ្ញាផ្ទាល់ និងបញ្ជូនសញ្ញានេះទៅអោយអ្នកបើកទូក។

**៨** ក្រោយពីអូសបាន ប្រហែល ២នាទី (ប្រហែលពី ១០០-១៥០ម) អ្នកមើលម៉ោងគួរផ្តល់ដំនឹងទៅអ្នកបើកទូកអោយឈប់មួយភ្លែតដើម្បីសរសេរកំនត់ត្រានូវអ្វីដែលបានឃើញ (ឧ. ដោយគោះខ្សែ ឬ ផ្លុំកញ្ចែប្រាប់)





បន្ទាប់មកអ្នកអង្កេតកត់បញ្ចូលទៅក្នុងក្តារឆ្នួននូវ លេខអូស និងការអង្កេតឃើញរបស់គាត់ក្នុងរយៈពេល ២ នាទីចុងក្រោយ នៅពេលនោះដែរ អ្នកបើកទូក ឬ អ្នកមើលម៉ោង គូសចំណាំនូវលេខអូសនៅលើទីតាំងកំពុងអង្កេតលើផែនទី។ ការដៅទីតាំងនៅលើផែនទី អាចប៉ាន់ប្រមាណបានដោយប្រើឧបករណ៍ប្រព័ន្ធទីតាំងពិភពលោក (GPS) ឬប្រើមាត្រដ្ឋាន និង គិតតាមរាងចតុកោណកែង ដោយប្រើត្រីវិស័យ។

**៩** ធ្វើបន្តពីវគ្គទី ៦ ដល់ ទី ៨ រហូតដល់ផែនការការអង្កេតអូសដោយទូកត្រូវបានបញ្ចប់




**១០** ចំលងទិន្នន័យបញ្ចូលទៅក្នុងតារាងទិន្នន័យទី ៣ និងភ្ជាប់នូវផែនទីមួយច្បាប់ (ផែនទីដែលមានលេខអូស និងគំនូស គន្លង) ជាមួយនឹងទិន្នន័យដើម។



11

បំលែងភាគរយនៃការគ្របដណ្តប់របស់ប្រភេទផ្កាថ្ម ដែលបានប៉ាន់ស្មានទៅជាពិន្ទុតាមកំរិត ៥ ថ្នាក់ ដូចខាងក្រោម:

| ពិន្ទុ | ភាគរយគ្របដណ្តប់នៃផ្កាថ្ម | និមិត្តសញ្ញា |
|---|---|---|
| ១ | ០-១០ % |  |
| ២ | ១១-៣០ % |  |
| ៣ | ៣១-៥០ % |  |
| ៤ | ៥១-៧៥ % |  |
| ៥ | ៧៦-១០០ % |  |

12

ចំលងពិន្ទុទាំងនោះដាក់លើផែនទី ។ ដាក់កំរិតពិន្ទុរបស់ផ្កាថ្មរឹងរស់អោយចំទីតាំងនីមួយៗលើគន្លងដែលបានអូសអោយត្រូវគ្នានឹងផែនទីធ្វើម៉ុងតាថូ ។




13

តាមរយៈពិន្ទុដែលបានដៅនៅលើផែនទី យើងអាចកំណត់ ជាក្រុមបាន ។ គូសជារង្វង់ព័ទ្ធជុំវិញក្រុមនីមួយៗ និង ធ្វើ ដូចគ្នាដែរតាមរយៈពិន្ទុប្រភេទផ្កាថ្មរឹងនៅលើផែនទី ។ ប៉ុន្តែអ្នកអាច ប្រើពិន្ទុផ្សេងៗទៀត ( ផ្កាថ្មទន់ ផ្កាថ្មងាប់ ។ល ។) និង ការ អង្កេតដើម្បីដាក់ទីតាំងក្រុមនីមួយៗជាផ្នែក ។



## ជំហ្វានគន្លឹះ

អនុវត្តហែលទឹកដោយប្រើបំពង់ខ្យល់ កំណាត់រៀនបែងចែក និងប៉ាន់ប្រមាណទៅលើភាគរយគ្របដណ្តប់ផ្កាថ្មរឹង ទន់ និង ងាប់នៅក្នុងតំបន់កំណត់មួយមុនពេលធ្វើម៉ុងតាថូ



ផ្កាថ្មរឹង

(HC)



ផ្កាថ្មទន់

(SC)



ផ្កាថ្មងាប់

(DC)



ផ្កាថ្មងាប់ដោយសារស្លែរុំព័ទ្ធ

(DCA)

## សញ្ញាប្រើពេលធ្វើម៉ុងតាថូ




OK រួចរាល់

អាចចាប់ផ្តើមបាន



STOP

ឈប់សិន



បត់ឆ្វេង



បត់ស្តាំ



បន្ថែមល្បឿន



បន្ថយល្បឿន



### ភាពខ្លាំង

ទីកន្លែងមានផ្ទៃធំអាចអង្កេតក្នុងរយះពេលខ្លីបាន ។

### ភាពខ្សោយ



☆ វិធីសាស្ត្រនេះអាចប្រើប្រាស់បានតែនៅតំបន់ទឹកថ្លាខ្ពស់ សមស្របអាច មើលបាន និង ក្នុងលក្ខខ័ណ្ឌសមុទ្រពុំមានខ្យល់ ។

តំលៃការវាស់វែងអាចប្រព្រឹត្តទៅបាន តែក្នុងករណីប្រហាក់ប្រហែលប៉ុណ្ណោះ

អាចធ្វើអោយអស់កំលាំង

# ទំរង់តារាងទិន្នន័យ ៣

# តារាងសំរង់ទិន្នន័យ ម៉ុងតាថូ

**តារាងសំរង់ទិន្នន័យ ម៉ុងតាថូ** — **តារាងទី ៣**

ឈ្មោះកន្លែងអង្កេត: កាបាកុងកាន  លេខ:  
ឈ្មោះទីក្រុង និងខេត្ត: ឡូន បូហុល

ពេលវេលា (ថ្ងៃ/ខែ/ឆ្នាំ): ០៤/២៦/១៩៩៩ ម៉ោង: ៤:០០-៥:០០ល្ងាច  
អ្នកអង្កេត: អាជ្រេ/ប៉ូលីន  
អ្នកមើលម៉ោង អ្នកមើលផែនទី អាជ្រេ

| លេខអូស | ពេលចាប់ផ្តើម | ទីតាំង: រយៈទទឹង បណ្តោយ ទិសនៃត្រីស័យ លក្ខណៈតំបន់ — ចំនុចចាប់ផ្តើម | ចំនុចបញ្ចប់ | ជំរៅទឹក ម៉ែត្រ | ផ្កាថ្មរឹង | ផ្កាថ្មទន់ | ផ្កាថ្មងាប់ | ផ្កាថ្មងាប់ជាមួយកំរោជាតិ | ខ្សាច់/ល្បាប់ | កំណត់សំគាល់ (ឧ. ផ្កាយសមុទ្រ ពោតច្រើន កាំប្រមាសមុទ្រ ស្លែសមុទ្រ ។ល។) |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ១៦:០៧:២៥ | ៩២៣°៤៦.៨៨៤ ៩°៥១.៧៩២ | ៩°៥១.៧៩៣ ១២៣°៤៦.៤០៤ | | ១០ | ៥ | ០ | | ៣០ | |
| ២ | ១៦:១០:០០ | ៩°៥១.៧៩២ ១២៣°៤៦.៤០៤ | ៩°៥១.៧២២ ១២៣°៤៦.៣៣០ | | ៧០ | ០ | ០ | | ៥ | |
| ៣ | ១៦:១២:៥០ | ៩°៥១.៧១៧ ១២៣°៤៦.៣២៧ | ៩°៥១.៦០៦ ១២៣°៤៦.១៦៧ | | ៧០ | ០ | ០ | | ០ | |
| ៤ | | ៩°៥១.៦៤៩ ១២៣°៤៦.២៤១ | ៩°៥១.៥៧០ ១២៣°៤៦.០៦៣ | | ៨៥ | ០ | ០ | | ០ | |
| ៥ | | | ៩°៥១.៥៧០ ១២៣°៤៦.០៦៣ | | | | | | | |
| ៦ | ១៦:២៦:៣៥ | ៩°៥១.៥៧០ ១២៣°៤៦.០៦៣ | | | ៨៥ | ០ | ០ | | ០ | |
| ៧ | ១៦ៈ២៩០០ | ៩°៥១៥៦៦ ១២៣°៤៥.៩៩៧ | ៩°៥១.៦១២ ១២៣°៤៥.៩០៧ | | ៨០ | ០ | ០ | | ៥ | |
| ៨ | ១៦ៈ៣២០០ | ៩°៥១៦១៧ ១២៣°៤៥.៨៩៥ | ៩°៥១.៦៨៣ ១២៣°៤៥.៨០១ | | ៣៥ | ០ | ០ | | ០ | |
| ៩ | ១៦ៈ៣៤៣០ | ៩°៥១៦៩២ ១២៣°៤៥.៧៩១ | ៩°៥១.៧៨ ០១២៣°៤៥.៧៤៧ | | ៣០ | ៥ | ០ | | ០ | |
| ១០ | ១៦ៈ៣៧០០ | ៩°៥១៧៥០ ១២៣°៤៥.៧៤៣ | | | ៣០ | ០ | ០ | ៥០ | ០ | |
| ១១ | ១៦ៈ៤០១៥ | ៩°៥១៩៣២ ១២៣°៤៥.៧១២ | ៩°៥១.៩៣២ ១២៣°៤៥.៧១២ | | ៦០ | ០ | ០ | ២០ | ១ | |

## ៧ ទូផលផែនទីគំរូ

ភាគរយគ្របដណ្ដប់នៃផ្កាថ្មរស់នឹងត្រូវបានគេដៅនៅលើផែនទីតាមរយៈលទ្ធផលដែលបានពីការអង្កេតដោយវិធីសាស្ត្រម៉ុងតាថូនៅចុងពាយនៃ Loon រដ្ឋ Bohol ។



## B. ការអង្កេតដោយប្រើបំពង់ខ្យល់ ( សំរាប់អ្នកហែលទឹកដែលប្រើបំពង់ខ្យល់សំរាប់ដកដង្ហើម)



### និយមន័យ

គឺជាវិធីសាស្ត្រដែលប្រើប្រាស់ដោយអ្នកហែលទឹកប្រើបំពង់ខ្យល់ដើម្បីប៉ាន់ស្មានភាពសំបូរបែបនៃសត្វមានជីវិត និងសត្វគ្មានជីវិតនៅប្រទាប់បាតសមុទ្រដែលគេអង្កេតនៅតាមតំបន់កំណត់មួយ ។

### គោលបំនង

ការអង្កេតដោយប្រើបំពង់ខ្យល់គឺដើម្បីប្រមាណទៅលើភាពសំបូរនៃផ្កាថ្មរឹង ផ្កាថ្មងាប់ ស្មៅ និង បែបផែននៅស្រទាប់បាត ផ្សេងៗទៀតដែលអាចឆ្លុះបញ្ចាំងពីសុខភាពរបស់ផ្កាថ្មបាន ។

### តំរូវការចាំបាច់

- ❑ រូបភាពគំរូសំរាប់ធ្វើការអង្កេត ។
- ❑ វ៉ែនតាហែលទឹក និង បំពង់ខ្យល់
- ❑ ខ្សែម៉ែត្រដែលមានប្រវែង ៥០ ម៉ែត្រ ( មានគំនូសសំគាល់រាល់ ៥ ម៉ែត្រម្តង)
- ❑ ក្តារឆ្នួនក្នុងទឹកសំរាប់ទ្រាប់ក្រដាស់សរសេរដែលមានភ្ជាប់ជាមួយនូវក្រដាស់សរសេរក្នុងទឹក និងខ្មៅដៃ

### តំរូវការបន្ទាប់បន្សំ

- ❑ ជើងទាសំរាប់ហែលទឹក
- ❑ អាវពោង

ពិនិត្យមើលទំរង់ជីវិតរស់នៅផ្សេងៗគ្នារបស់សត្វ និងរៀនធ្វើអត្តសញ្ញាណកម្មទៅលើទំរង់ជីវិត្តនៃសត្វផ្សេងៗឧទាហរណ៍ដើម្បីអោយដឹងពីទំរង់ជីវិត្តនៃសត្វទាំងនោះនៅកងតំបន់មួយជាដំបូង គឺត្រូវវាយតំលៃពីភាពជាក់ស្តែងជាមុនសិន ។



**១**

ជ្រើសរើសស្ថានីយ៍គំរូសំរាប់អង្កេត ឬត្រួតពិនិត្យដោយយោងលើលទ្ធផលនៃវិធីសាស្ត្រម៉ុងតាថូ។



**២**

ចំលងតារាងទិន្នន័យ ៖៤ (ទំរង់ជីវិតស្រទាប់បាតដែលបានជ្រើសរើស) ទៅលើក្តារឆ្នួនជ័រដែលប្រើសំរាប់សរសេរក្នុងទឹក។




**៣**

ដាក់ខ្សែម៉ែត្រទៅតាមស្ថានភាពបាតសមុទ្រក្នុងជំរៅទឹកកំណត់មួយ។ ធ្វើការកត់ត្រាជំរៅទឹក។.




**៤**

ការអង្កេតគឺចាប់ផ្តើមពីចំនុចដើមលើខ្សែម៉ែត្រដោយហែលពីលើខ្សែម៉ែត្រ និងអង្កេតទៅលើទំរង់ជីវិតសត្វស្រទាប់បាតចំងាយ ២,៥ ម៉ែត្រសងខាងខ្សែ និងមើលទៅមុខ៥ ម៉ែត្រម្តង។ ការគណនាគឺអង្កេត ៥ ម៉ែត្រម្តងនោះមានក្រឡាផ្ទៃ ២៥ ម៉ែត្រការេ។




**៥**

ធ្វើការកត់ត្រាដូចគ្នានៅក្នុងចន្លោះ៥ ម.ម្តង រហូតដល់ចុងខ្សែម៉ែត្រ (៥០ម)។



**៦**

បូកបញ្ចូល ១០ ដងនូវលទ្ធផលនៃការអង្កេត ហើយចែកនិង ១០ ដើម្បីរកមធ្យមភាគ។

| | | TOTAL |
|---|---|---|
| HC | 23+42+35 +40+14+16+ 24+27+32 +30 | 28.3 |

**៧** ធ្វើចំណាត់ថ្នាក់តំបន់ខ្សែម៉ែត្រនីមួយៗដោយយោងទៅតាមគោលបំណងរបស់អ្នកសំរាប់សង្ខេបទិន្នន័យ ។ ឧទាហរណ៏:

* * តំបន់ ឬបែបផែននៃផ្កាថ្ម ( ឧ.តំបន់ផ្កាថ្មសណ្ឋានរាបស្មើ តំបន់ផ្កាថ្មសណ្ឋានល្បាក់ និងតំបន់ផ្កាថ្មជាប់ និងឆ្ងាយពីដីគោក ។ល ។)
* * ពេលវេលាការនៃអង្កេតគំរូ ( ឆ្នាំទី១/រដូវប្រាំង, ឆ្នាំទី១/រដូវវស្សា, ឆ្នាំទី២/រដូវភ្លៀង ។ល ។)
* * ការគ្រប់គ្រង ឬ ប្រើប្រាស់នៅក្នុងតំបន់ ( ទីជំរកបំរុងទុក តំបន់ នេសាទ)
* * កំរិតផលប៉ះពាល់ ( កំរិតបំពុលខ្ពស់ កំរិតបំពុលមធ្យម និងកំរិត បំពុលទាប)
* * កត់ត្រាតំបន់ដាក់ខ្សែម៉ែត្រជាក្រុមតាមបណ្ដោយផ្នែកខាងលើនៃតារាងសង្ខេប ។

**៨** កត់ត្រាបែបផែនជីវិតសត្វនៅស្រទាប់បាត ( ទៅតាមក្រុម) នៅផ្នែកខាងឆ្វេងនៃតារាងសង្ខេប




**៩** ចំលងទិន្នន័យភាគរយគ្របដណ្តប់របស់ជីវិតសត្វស្រទាប់បាតពីតំបន់ខ្សែម៉ែត្រនីមួយៗទៅក្នុងតារាងសង្ខេប

| TRANSECT | 1 | 2 | 8 | 9 | 16 | |
|---|---|---|---|---|---|---|
| TYPES/ GROUPS | SUBTOTAL | | | | | |
| HC | 15% | 6% | 5% | 10% | | |
| SC | 58% | 10% | 22% | 76% | | |
| DC | | | | | | |

**១០** គណនានូវទិន្នន័យសរុបអំពីជីវិតសត្វស្រទាប់បាតទៅតាមខ្សែម៉ែត្រនីមួយៗដូចទំរង់ក្រាភិច ៤យ

| SECT | 1 | 2 | 8 | 9 | 10 | TOTAL |
|---|---|---|---|---|---|---|
| TYPES/ GROUPS | SUBTOTAL | | | | | |
| HC | 15% | 6% | 5% | 10% | | 36 |
| SC | 58% | 10% | 22% | 76% | | 166 |
| DC | | | | | | |

**១១** ធ្វើអោយមានលក្ខណ:គំរូនូវលទ្ធផលសរុបទៅតាមកន្លែងអង្កេត ចែកភាគរយសរុបនឹងចំនួនតំបន់ខ្សែម៉ែត្រដែលបានអង្កេត ។ សរសេរលទ្ធផលជាមធ្យមភាគក្នុងតារាងជួរបញ្ឈរ ។

| TRANSECT # | 1 | 2 | 8 | 9 | 10 | | TOTAL | AVER |
|---|---|---|---|---|---|---|---|---|
| TYPE/ GROUPS | SUBTOTAL | | | | | | | |
| SOFT CORAL | 15% | 6% | 5% | 10% | | | 36 | 9% |
| HARD CORAL | 58 | 10% | 22% | 76% | | | 166 | 41.5% |
| | | | | | | | | |

**ឧទាហរណ៏**

៤៣% + ៨% + ២០% + ៣២% + ១៧% = ២៤%

៥ ខ្សែម៉ែត្រ

**១២** គូសរូបក្រាភិចតំណាងមធ្យមភាគជាភាគរយគ្របដណ្តប់របស់ជីវិតសត្វស្រទាប់ទៅតាមតំបន់ខ្សែម៉ែត្រនីមួយៗដោយដាក់ជាក្រុមដូចតារាង ៤D ក្រាភិច



## សត្វ និង រុក្ខជាតិមានជីវិតស្រទាប់បាតសមុទ្រ



ផ្កាថ្មរឹង

(HC)



ផ្កាថ្មទន់

(SC)







ស្លែល្អិតៗ

(សារាសៃតូចៗ)

ផ្កាថ្មងាប់

(ពណ៌សដោយគ្មានជាលិការស់នៅលើវា)

ដីខ្សាច់/ល្បាប់







ស្លែដែលមានទំហំធំ

(អាចបោចបានដោយដៃ)

ផ្កាថ្មងាប់ដោយមានស្លែរុំ

(ឆ្អឹងផ្កាថ្មដែលនៅអាចមើលស្គាល់)

កំទិចថ្ម/ដុំថ្ម

(កំទេចថ្ម/បំណែកផ្កាថ្ម)



ស្លែដែលមានលក្ខណៈរឹង ពណ៌ផ្កាឈូក ឬក្រហមនៅផ្ទៃកខាងលើនៃផ្កាថ្ម



## ភាពខ្លាំង

ការធ្វើចំនាត់ថ្នាក់ពពួកសត្វមានជីវិតទាំងនោះមិនចាំបាច់មានចំនេះដឹងខាងឋានានិរ្ទ័យសាស្រ្តផ្កាថ្មឡើយ ។



## ភាពខ្សោយ

១ ពេលខ្លះមានការភាន់ច្រលំថាតើត្រូវធ្វើការបែងចែកពពួកសត្វមានជីវិតដូចម្តេច? (ចូលធ្វើលំហាត់ជាមួយគ្រូបង្រៀនរបស់អ្នក)

២ បើគ្មានចំនួនគំរូគ្រប់គ្រាន់ វាជាការលំបាកក្នុងការយកអោយបានពតិមានជាក់លាក់ពីការផ្លាស់ប្តូរតាមពេលវេលា ។

## គ. វិធីសាស្ត្ររាប់ចំនុចនៅលើតំបន់ខ្សែម៉ែត្រ (សំរាប់អ្នកមុជទឹកដោយប្រើធុងខ្យល់)




**និយមន័យ:**

វិធីសាស្ត្ររាប់ចំនុចនៅលើខ្សែម៉ែត្រជាវិធីសាស្ត្រមួយ ប្រើដោយអ្នកមុជទឹកសំរាប់វាយតំលៃភាពសំបូរបែបនៃសត្វមានជីវិត និង គ្មានជីវិតនៅតំបន់ផ្កាថ្ម។

**គោលបំនង:**

វិធីសាស្ត្ររាប់ចំនុចនៅលើខ្សែម៉ែត្រត្រូវបានគេប្រើក្នុងគោលបំនងវាយតំលៃយ៉ាងជាក់លាក់នូវភាពសំបូររបស់ផ្កាថ្មរឹង និង ផ្កាថ្ម ងាប់ វារិជាត និង បែបផែនបាតសមុទ្រផ្សេងៗ ដែលអាចឆ្លុះបញ្ចាំងនូវសុខភាពរបស់ផ្កាថ្មបាន។

**តំរូវការចាំបាច់:**

- ☐ សៀវភៅរូបភាពប្រភេទសត្វនិង រុក្ខជាតិ
- ☐ សំភារៈសំរាប់មុជទឹកដោយប្រើធុងខ្យល់
- ☐ ខ្សែម៉ែត្រប្រវែង ៥០ម (ដែលមានចំនុចក្រឹតត្រង់ចំនុច ០,២៥មម្តង)
- ☐ ក្តារឆ្នួនជ័រ ដែលអាចសរសេរក្នុងទឹកបាន និង មានភ្ជាប់ខ្មៅដៃសរសេរ
- ☐ អ្នកមុជទឹកដែលមានវិញ្ញាបនប័ត្រត្រឹមត្រូវ

**តំរូវការបន្ទាប់បន្សំ**

- ☐ ទូក (អាស្រ័យនឹងទីកន្លែងធ្វើអង្កេត)



១ ជ្រើសរើសស្ថានីយ៍គំរូសំរាប់ធ្វើការអង្កេត ឬត្រួតពិនិត្យដោយផ្អែកលើលទ្ធផលនៃវិធីសាស្ត្រម៉ង់តាថូ




២ ចំលងតារាងទិន្នន័យ( ដែលបានសរសេរអំពីបែបផែនជីវិតសត្វស្រទាប់បាត) លើក្តារឆ្នួនជ័រដែលនឹងត្រូវប្រើសំរាប់សរសេរក្នុងទឹក ។




៣ ដាក់ខ្សែម៉ែត្រទៅតាមសណ្ឋាន និងជំរៅបាតសមុទ្រថេរមួយ ។ ហើយកត់ត្រាជំរៅទឹក




៤ ចាប់ផ្តើមពីចំនុចដើមនៃខ្សែម៉ែត្រ ។ អ្នកអង្កេតធ្វើការកំណត់ប្រភេទជីវិតសត្វស្រទាប់បាតដែលនៅពីក្រោមខ្សែម៉ែត្រផ្ទាល់ក្នុងចន្លោះប្រវែង ០.២៥ ម៉ែត្រម្តង និង ចំលងទិន្នន័យចូលក្នុងតារាង ។




៥ ធ្វើដូចគ្នានេះដែរចំពោះស្ថានីយ៍ផ្សេងៗទៀតរហូតដល់ចប់សព្វគ្រប់ទៅតាមផែនការ ។




៦ ភាគរយគ្របដណ្តប់របស់សត្វស្រទាប់បាតនីមួយៗស្មើនឹងចំនួនដងនៃសត្វស្រទាប់បាតដែលបានអង្កេតចែកនឹងចំនួនសរុបនៃចំនុចដែលត្រូវអង្កេត ។




ឧទាហរណ៍

$$\frac{\text{ផ្កាថ្មទន់ ៣០ ចំនុច}}{\text{ចំនុចអង្កេត ២០០ ចំនុច}} = \text{ផ្កាថ្មទន់ ១៥ \%}$$

**៧** ធ្វើចំណាត់ថ្នាក់តំបន់ខ្សែម៉ែត្រផ្សេងៗគ្នាទៅតាមគោលបំនងបំណងនៃការសង្ខេបទិន្នន័យរបស់អ្នក ។ ឧទាហរណ៍ៈ

* តំបន់ឬបែបផែនផ្កាថ្ម (ឧ.តំបន់ផ្កាថ្មសណ្ឋានរាបស្មើ តំបន់ផ្កាថ្មសណ្ឋានល្បាក់ តំបន់ផ្កាថ្មជាប់ដីគោក តំបន់ផ្កាថ្មឆ្ងាយពីដីគោក ។)
* ពេលវេលានៃការអង្កេតគំរូ (ឆ្នាំទី១/រដូវប្រាំង ឆ្នាំទី១/រដូវវស្សា ឆ្នាំទី២/រដូវប្រាំង ។ល ។)
* តំបន់គ្រប់គ្រង ឬ ប្រើប្រាស់(ទីជំរកបំរុងទុក តំបន់នេសាទ)
* កំរិតការនៃប៉ះពាល់ (ឧ.ការបំពុលមានកំរិតខ្ពស់ កំរិតមធ្យម និងការបំពុលកំរិតទាប)
* រាយបញ្ជីនៃតំបន់ខ្សែម៉ែត្រទៅតាមក្រុមនៅផ្នែកខាងលើនៃតារាងទិន្នន័យសង្ខេប

**៨** កត់ត្រាបែបផែនជីវិតសត្វស្រទាប់បាត(នៅផ្នែកខាងឆ្វេងនៃតារាងសង្ខេប)

DATA SUMMARY FORM

| | OUTSIDE | | | | | INSIDE | | | | |
|---|---|---|---|---|---|---|---|---|---|---|
| TRANSECT # | 1 | 2 | 8 | 9 | 10 | 4 | 5 | 6 | 7 | 8 |
| TYPE & GROUPS | | | | | | | | | | |
| HC | | | | | | | | | | |
| SC | | | | | | | | | | |
| DC | | | | | | | | | | |
| DCA | | | | | | | | | | |
| TA | | | | | | | | | | |
| MA | | | | | | | | | | |
| CA | | | | | | | | | | |
| SP | | | | | | | | | | |

**៩** ចំលងទិន្នន័យភាគរយគ្របដណ្តប់បែបផែនជីវិតសត្វស្រទាប់បាតតាមតំបន់ខ្សែម៉ែត្រនីមួយៗទៅក្នុងតារាងសង្ខេប ។

| TRANSECT | 1 | 2 | 8 | 9 | 10 | |
|---|---|---|---|---|---|---|
| TYPES/ GROUPS | SUBTOTAL | | | | | |
| HC | 15% | 6% | 5% | 10% | | |
| SC | 58% | 10% | 22% | 76% | | |
| DC | | | | | | |

**១០** គណនានូវទិន្នន័យសរុបអំពីជីវិតសត្វស្រទាប់បាតទៅតាមតំបន់ខ្សែម៉ែត្រនីមួយៗដូចទំរង់ក្រាភិច ៤យ

| SECT | 1 | 2 | 8 | 9 | 10 | TOTAL |
|---|---|---|---|---|---|---|
| TYPES/ GROUPS | SUBTOTAL | | | | | |
| HC | 15% | 6% | 5% | 10% | | 36 |
| SC | 58% | 10% | 22% | 76% | | 166 |
| DC | | | | | | |

**១១** ធ្វើអោយមានលក្ខណៈគំរូនូវលទ្ធផលសរុបទៅតាមកន្លែងអង្កេត ចែកភាគរយសរុបនឹង ចំនួនតំបន់ខ្សែម៉ែត្រដែលបានអង្កេត ។ សរសេរលទ្ធផលជាមធ្យមភាគទៅក្នុងតា រាងជូរបញ្ឈរ ។

| TRANSECT # | 1 | 2 | 8 | 9 | 10 | | TOTAL | AVER |
|---|---|---|---|---|---|---|---|---|
| TYPE/ GROUPS | SUBTOTAL | | | | | | | |
| SOFT CORAL | 15% | 6% | 5% | 10% | | | 36 | 9% |
| HARD CORAL | 58 | 10% | 22% | 76% | | | 166 | 41.5% |
| | | | | | | | | |

**ឧទាហរណ៍ :**

$$\frac{១៥\% + ៦\% + ៥\% + ១០\% = ៩\%}{៤ \text{ ខ្សែម៉ែត្រ}}$$

**១២** គូសក្រាភិចតំណាងមធ្យមភាគជាភាគរយគ្របដណ្តប់របស់ជីវិតសត្វរុក្ខជាតិស្រទាប់បាតទៅតាមខ្សែម៉ែត្រនីមួយៗដោយដាក់ជាក្រុមដូចតារាងក្រាភិច៤យ ។



# តារាងគំរូទិន្នន័យ ក ៤ បង្ហាញពីការប្រើប្រាស់ខ្សែម៉ែត្រ ដែលមានប្រវែង ៥០ ម៉ែត្រ ដោយប្រើស្លកខែលសំរាប់ការអង្កេត

## តារាងកត់ត្រាទិន្នន័យទំរង់ស្រទាប់បាត និងសត្វឥតឆ្អឹងកង — គំរូទី ៤ក

| ឈ្មោះទីកន្លែង: គីឡូតុងកាន់ តំបន់នេសាទសមុទ្របំរុងទុក | ឈ្មោះទីក្រុង និងខេត្ត: គំរដូវ៉ា សេប៊ូ |
|---|---|
| លេខខ្សែព័ន្ធកាត់: ១ ធុងខ្យល់: បំពង់ខ្យល់: ✓ | ទីតាំងភូមិសាស្ត្រ: ១០°១២.៧០១ខាងជើង, ១២៣°៥៩.៣០១ខាងកើត |
| ពេលវេលា (ថ្ងៃ/ខែ/ឆ្នាំ): ១១/៤/៩៩ | អ្នកអង្កេតស្រទាប់បាត: អាមូឡូ អ្នកអង្កេតពពួកសត្វឥតឆ្អឹងកងខ្នង: ដាយអូឡា |
| ការមើលឃើញក្នុងទឹកតាមខ្សែដេក (ម): | ជំរៅទឹក (ម): ៣.៥ម ; តំបន់ផ្កាថ្ម: ជំរាលខាងមុខ ; ស្ថានភាពបាតសមុទ្រ: ជំរាលល្មម ; ចំនោត: |
| កត់សំគាល់ទីជំរក: | |

| ពពួកសត្វ រុក្ខជាតិស្រទាប់បាត: | | ភាគរយដែលមានដោយបែបផែននៃសត្វ និងរុក្ខជាតិនិមួយៗ | | | | | ការរាប់សរុប | ភាគរយគ្រប់ដណ្តប់ |
|---|---|---|---|---|---|---|---|---|
| ផ្កាថ្មរស់ | HC ផ្កាថ្មរឹង | ២៥ ១០ | ១៥ ៨ | ៨ ៥ | ១៧ ១០ | ១៨ ២៣ | ១៣៩ | ១៣.៩% |
| | SC ផ្កាថ្មទន់ | ០ ១០ | ០ ១៥ | ០ ៥ | ៥ ០ | ០ ០ | ៣៥ | ៣.៥% |
| ផ្កាថ្មងាប់ | DC ផ្កាថ្មងាប់ពណ៌ស | ០ ០ | ៣ ០ | ០ ០ | ០ ៥ | ០ ០ | ៨ | ០.៨% |
| | DCA ផ្កាថ្មងាប់មានស្លែរុំ | ០ ៦ | ០ ០ | ២ ០ | ០ ៣ | ០ ០ | ១១ | ១.១% |
| សត្វផ្សេងៗ | SP ស្ពង់ | ០ ០ | ០ ០ | ០ ០ | ០ ០ | ០ ០ | ០ | ០% |
| | OT សត្វផ្សេងៗ | ០ ០ | ០ ០ | ០ ០ | ០ ០ | ០ ០ | ០ | ០% |
| ពពួករុក្ខជាតិ | TA ស្លែសមុទ្រតូចៗ | ៤៦ ៤៣ | ៣២ ២ | ៤០ ៣៥ | ៤៩ ៤៧ | ៤៩ ៤៧ | ៣៦៧ | ៣៦.៧% |
| | MA ស្លែសមុទ្រធំៗ | ១៤ ៨ | ១៥ ២០ | ១០ ៥ | ៨ ៥ | ៨ ៥ | ១០៥ | ១០.៥% |
| | CA ស្លែកំបោរ | ០ ៣ | ០ ៥ | ០ ០ | ០ ០ | ០ ០ | ១២ | ១.២% |
| | SG ស្មៅសមុទ្រ | ០ ០ | ០ ០ | ០ ០ | ០ ០ | ០ ០ | ០ | ០% |
| ពពួកគ្មានជីវិត | R កំទិច | ០ ០ | ០ ០ | ០ ២០ | ០ ១៥ | ០ ១៥ | ៥០ | ៥% |
| | RCK ថ្ម | ០ ៥ | ១០ ៥ | ០ ៥ | ៥ ០ | ០ ១៥ | ៣៣ | ៣.៣% |
| | S/SI ខ្សាច់ ល្បាប់ | ១៥ ១៥ | ២៥ ៤៥ | ៤០ ២៥ | ៣០ ១៥ | ២០ ១០ | ២៤០ | ២៤% |
| សរុប | | | | | | | ១០០០ | ១០០% |

| ពពួកសត្វឥតឆ្អឹងកងខ្នង | មើលក្នុងចន្លោះ ទទឹង ៥ ម |
|---|---|
| កាំប្រមាសមុទ្រ | ៤៥ |
| កាំប្រមាសមុទ្រខ្មៅដៃ | |
| កាំប្រមាសមុទ្រយក្ស | |
| គ្រុំយក្ស | |
| ខ្យងយក្ស | |
| បង្កងសមុទ្រ | |
| ឈ្លូងសមុទ្រ | |
| បង្គាផ្កាថ្មក្រឡា | |
| ផ្សេងៗ | |

**មូលហេតុបណ្តាលអោយខូចផ្កាថ្ម:**

បើមានអ្វីកើតឡើងចំពោះផ្កាថ្មសូមគូសខ្វែងពីក្នុងប្រអប់ខាងក្រោម ។ គូសរង្វង់ ពន្ធ័ជុំវិញប្រអប់ក្នុងករណីសំបូរ:

- [ ] កករដី
- [ ] សារាយសមុទ្រច្រើនហួសពីលើ
- [ ] ដោយការដាក់គ្រឿងផ្ទុះ
- [ ] ខ្យងស៊ីផ្កាថ្ម
- [x] បំផ្លាញដោយយុថ្កា
- [ ] ផ្កាយសមុទ្រយក្ស
- [ ] ការបំផ្លាញផ្សេងៗ
- [ ] សំរាមជ័រប្លាស្ទិច
- [ ] ផ្កាថ្មងាប់ដោយរលួយ
- [ ] សំរាមផ្សេងៗ
- [ ] មានជំងឺបណ្តុំខ្មៅ
- [ ] មូលហេតុផ្សេងៗ (បញ្ជាក់ខាងក្រោម)
- [ ] មានជំងឺបណ្តុំស
- [ ] ផ្កាថ្មមានជំងឺផ្សេងៗ

គំរូតារាងសង្ខេបទិន្នន័យពីលទ្ធផលនៃការអង្កេត១០ដងតាមវិធីសាស្ត្ររាប់ចំនុចតាមខ្សែម៉ែត្រដែលមានប្រវែង ៥០ ម៉ែត្រ

| តារាងសំរង់ទិន្នន័យសង្ខេប | | | | | | | | | | | | | | | | | តំរង់ ៤គ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះទីកន្លែង: គីឡូត្រុងកាន កន្លែងបំរុងទុកសមុទ្រ | | | | | | | | | ឈ្មោះទីក្រុង និងខេត្ត: ករជូវ៉ា ស៊ីបូ | | | | | | | | |
| តំបន់/ផ្នែក: | ផ្នែកខាងក្រៅ | | | | | | | | ផ្នែកខាងក្នុង | | | | | | | | |
| ខែ និង ឆ្នាំ: | ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ | | | | | | | | ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ | | | | | | | | |
| ចំនួនខ្សែម៉ែត្រ: | ១ | ២ | ៣ | ៩ | ១០ | | | | ៤ | ៥ | ៦ | ៧ | ៨ | | | | |
| បែបផែន/ក្រុមនៃ សត្វរុក្ខជាតិ | សរុប | | | | | | សរុប | មធ្យម | សរុប | | | | | | | សរុប | មធ្យម |
| ផ្កាថ្មរឹង | ៤៤.០% | ២៨.០% | ៥៦.៥% | ៤១.០% | ១៥.៣% | | ១៨៤.៨ | ៣៧% | ៦៥.០% | ៦១.៥5 | ២១.១% | ៤២.៥% | ៣៨.៥% | | | ២២៨.៦ | ៤៥.៧% |
| ផ្កាថ្មទន់ | ០.០% | ០.០% | ០.០% | ០.០% | ០.៥% | | ០.៥ | ០% | ០.៥% | ០.០% | ០.៥% | ០.៥% | ០.០% | | | ១.០ | ០.២% |
| ផ្កាថ្មងាប់ពណ៌ស | ០.០% | ០.០% | ០.០% | ០.០% | ០.០% | | ០.០ | ០% | ០.០% | ០.០% | ៤.០% | ៦.៥% | ១.០% | | | ១១.៥ | ២.៣% |
| ផ្កាថ្មងាប់ជាប់ស្លែ | ៤.០% | ៥.០% | ៩.០% | ៧.០% | ២.៦% | | ២៧.៦ | ៦% | ៩.០% | ១២.០% | ១៣.៦% | ១៨.០% | ១២.០% | | | ៦៤.៦ | ១២.៩% |
| ស្លង់ | ០.០% | ០.០% | ០.០% | ០.៥% | ០.៥% | | ១.០ | ០% | ២.០% | ១.០% | ១.៥% | ២.០% | ១.០% | | | ៧.៥ | ១.៥% |
| សត្វផ្សេងៗ | ០.០% | ០.០% | ០.០% | ០.០% | ០.៥% | | ០.៥ | ០% | ១.០% | ០.០% | ១.៥% | ០.០% | ០.៥% | | | ៣.០ | ០.៦% |
| ស្លែតូចៗ | ០.០% | ០.០% | ៧.៥% | ០.០% | ០.០% | | ៧.៥ | ២% | ០.០% | ០.០% | ០.០% | ០.០% | ០.៥% | | | ០.៥ | ០.១% |
| ស្លែធំៗ | ១១.៥% | ២៧.៥% | ០.០% | ០.០% | ០.៥% | | ៣៩.៥ | ៨% | ០.០% | ០.០% | ០.០% | ០.៥% | ០.០% | | | ០.៥ | ០.១% |
| ស្លែកំបោរ | ០.៥% | ០.០% | ០.០% | ០.០% | ០.៥% | | ១.០ | ០% | ០.០% | ០.០% | ០.៥% | ០.០% | ០.០% | | | ០.៥ | ០.១% |
| ស្មៅសមុទ្រ | ០.០% | ០.០% | ០.០% | ០.០% | ២.៦% | | ២.៦ | ១% | ០.០% | ០.០% | ០.០% | ០.០% | ០.០% | | | ០.០ | ០.០% |
| កំទេចថ្ម | ៦.០% | ៩.៥% | ៦.៥% | ៥.០% | ០.៥% | | ២៧.៥ | ៦% | ៩.៥% | ៩.៥% | ១៧.១% | ៩.៥% | ១៤.០% | | | ៥៩.៦ | ១១.៩% |
| ថ្ម | ១៤.៥% | ១៥.០% | ៩.៥% | ៤.០% | ៦.៦% | | ៤៩.៦ | ១០% | ៨.០% | ៧.០% | ៥.៥% | ៣.០% | ២.០% | | | ២៥.៥ | ៥.១% |
| ខ្សាច់/ភក់ | ១៩.៥% | ១៥.០% | ១១.០% | ៤២.៥% | ៦៩.៥% | | ១៥៧.៥ | ៣២% | ៥.០% | ១២.០% | ៣២.២% | ១៧.៥% | ៣០.៥% | | | ៩៧.២ | ១៩.៤% |
| | | | | | | | | | | | | | | | | | |
| សត្វឥតឆ្អឹងកងខ្នង | | | | | | | | | | | | | | | | | |
| កាំប្រមាសមុទ្រ | ៧ | ២១ | ២ | ៥ | ៣ | | ៣៨ | ៧.៦ | ? | ៩២ | ៦ | ៦ | ? | | | ១០៤ | ៣៥ |
| ឈ្លើងសមុទ្រ | ១ | ០ | ១ | ២ | ២ | | ៦ | ១.២ | ? | ០ | ២ | ១ | ? | | | ៣ | ១ |

| ទំរង់ក្រាភិចពពួកស្រទាប់បាត | | | ទំរង់ ៤ឃ |
|---|---|---|---|
| ឈ្មោះកន្លែង : សមុទ្របំរុងទុក សេបូ | | ឈ្មោះទីក្រុង និងខេត្ត: កូដូវា, សេបូ: | |
| ខែ និង ឆ្នាំ: | ខែ មិនា ឆ្នាំ ១៩៩៩ | ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ | |
| ប្រភេទ ក្រុម | | | |




សូមមើលការណែនាំបន្ថែមនៅទំព័រទី ៣៤

## ការសិក្សានៅក្នុងមន្ទីរពិសោធន៍



ដោយប្រើរូបគំនូខាងក្រោមនេះ ដើម្បីប៉ាន់ស្មានពីភាគរយគ្រប់ដណ្តប់នៃបែបផែនជីវិតសត្វ និងរុក្ខជាតិស្រទាប់បាតដែលឃើញតាមខ្សែម៉ែត្រនីមួយៗ។ ចូរប្រើបន្ទាត់អោយដូចជាខ្សែម៉ែត្រដើម្បីអនុវត្តន៍ការអង្កេតដោយប្រើបំពងខ្យល់ ឬរាប់ចំនុចនៅតាមខ្សែម៉ែត្រ។ សូមកុំប្រើបន្ទាត់ឬខ្សែម៉ែត្រពេលអនុវត្តនីវិធីសាស្រ្តម៉ុងតាថូ។

តំបន់ខ្សែម៉ែត្រ ក



តំបន់ខ្សែម៉ែត្រ ខ



## ដំបូន្មានរបស់អ្នកបង្រៀនក្នុងជំពូក ៥

វិធីសាស្ត្រសំរាប់ប៉ាន់ប្រមាណភាគរយគ្របដណ្តប់នៃសត្វ និងរុក្ខជាតិស្រទាប់បាតដោយបំពង់ខ្យល់ដូចបាន ពិពណ៌នាក្នុងសៀវភៅនេះ គឺជាវិធីសាស្ត្រម៉ង់តាថូដែលត្រូវបានគេធ្វើអោយប្រសើឡើង និងត្រូវបានប្រើប្រាស់ជាប្រចាំ ដោយវិទ្យាស្ថានវិទ្យាសាស្ត្រសមុទ្រអូស្ត្រាលី និងប្រព័ន្ធវិធីសាស្ត្រហែលទឹកដោយប្រើបំពង់ខ្យល់ដែលបានបង្កើតឡើង និងធ្វើការសាកល្បងដោយលោក White *et al.* (២000) ជាមួយអ្នកស្ម័គ្រចិត្តនៃក្រុមពិនិត្យផែនដី និង ក្រុមអង្កេតផ្សេងទៀត។

ខ្សែម៉ែត្រត្រូវបានគេដាក់ក្នុងជំរៅទឹកកំណត់មួយ (លើកលែងតែអ្នកអង្កេតចង់ធ្វើតាមគំនូសកាត់ តាមជំរៅទឹកផ្សេងៗ តែទោះជាយ៉ាង ណាក៏ដោយ ការស្រង់ទិន្នន័យត្រូវស្រង់ឡើងផ្សេងគ្នាទៅតាមជំរៅទឹកទាំងនោះ)។ រាយខ្សែម៉ែត្រអោយស្របទៅតាមគន្លងបាតទឹក ហើយបើជួបដំថ្មធំៗត្រូវរាយខ្សែម៉ែត្រព័ទ្ធជុំវិញ (ជៀសវាងទាញ ខ្សែម៉ែត្រឡើងលើ) ធ្វើដូចនេះដើម្បីអោយខ្សែម៉ែត្រក្នុងជំរៅទឹកថេរមួយ។

### សំនួរសារឡើងវិញ

1. តើអ្នកដឹងពីភាពខុសគ្នារវាងផ្កាថ្មរឹងដែលនៅរស់និង ផ្កាថ្មរឹងដែលងាប់បានយ៉ាងដូចម្តេច?
2. តើអ្នកដឹងពីភាពខុសគ្នារវាងផ្កាថ្មរឹង និង ផ្កាថ្មទន់បានយ៉ាងដូចម្តេច?

ផ្កាថ្មរឹងរស់ជាទូទៅមានពណ៌ផ្សេងៗ។ ផ្កាថ្មរឹងងាប់មានពណ៌សតែគ្មានជាលិកាទេ។ ផ្កាថ្មរឹងដែលមានរ៉ារិជាត រស់នៅពីលើ (មិននៅខាងក្នុង) គឺវាងាប់ស្ទើរតែទាំងអស់ឬកំពុងតែងាប់។

# ការអង្កេតមើលពពួកត្រីក្នុងតំបន់ផ្កាថ្ម

## វិធីសាស្ត្ររាប់ត្រីដោយភ្នែកផ្ទាល់

## ៦



### និយមន័យ:

វិធីសាស្ត្ររាប់ត្រីដោយភ្នែកផ្ទាល់គឺជាការអង្កេតដើម្បីកំណត់អត្តសញ្ញាណត្រី និងរាប់ប្រភេទត្រីផ្សេងៗ នៅក្នុងតំបន់ កំណត់មួយ ។

### គោលបំណង:

វិធីសាស្ត្ររាប់ត្រីដោយភ្នែកផ្ទាល់អាចប្រើសំរាប់ធ្វើការប៉ាន់ស្មានអំពីចំនួន និងទំហំត្រី ។ នៅក្នុងតំបន់ដែល មានកិរិតថ្លាខ្ពស់វិធីសាស្ត្រ នេះងាយមើលឃើញ និង ងាយកំណត់អត្តញ្ញាណប្រភេទត្រីផ្សេងៗ ។ ពត៌មាននេះអាចឆ្លុះបញ្ចាំងពីសុខភាព នៃផលស្តុកត្រីនៅក្នុងតំបន់ផ្កាថ្មដែលបានអង្កេត ។

### តំរូវការចាំបាច់:

- ❑ សៀវភៅរូបភាពសត្វ( ឧ.ប្រភេទត្រីតំបន់ផ្កាថ្ម) ដែលត្រូវរាប់ ។
- ❑ វ៉ែនតាហែលទឹកនិងបំពង់ខ្យល់សំរាប់ដកដង្ហើម
- ❑ ខ្សែម៉ែត្រប្រវែង ៥០ម មួយ ឬ ពីរខ្សែដែលមានចំនុចក្រិត ៥ម ម្តង
- ❑ ក្តារឆ្នួនដែលមានភ្ជាប់ខ្មៅដៃសំរាប់សរសេរក្នុងទឹក

### តំរូវការបន្ទាប់បន្សំ

- ❑ ទូក ( អាស្រ័យទៅតាមតំបន់ដែលត្រូវធ្វើអង្កេត)
- ❑ សៀវភៅណែនាំអំពីការកំណត់អត្តសញ្ញាណប្រភេទត្រីដែលមិនជ្រាបទឹក ( បើសិនជាអ្នកអង្កេតមិនសូវស្គាល់ច្បាស់អំពីប្រភេទ ឬពួកត្រីនីមួយៗ)
- ❑ សៀវភៅណែនាំអំពីការកំណត់អត្តសញ្ញាណប្រភេទត្រីមេអំបៅ ដែលមិនជ្រាបទឹក( បើសិនប្រភេទត្រីនេះត្រូវបានយកធ្វើជាសន្ទស្សន៍)
- ❑ ជើងទាហែលទឹក
- ❑ អាវពោង





១
ជ្រើសរើសស្ថានីយ៍គំរូនិងពពួកត្រីដែលត្រូវរាប់ ។
MAP
N
FISH GUIDE
សំរាប់ស្ថានីយ៍នីមួយៗ ត្រូវធ្វើតាមជំហានទី ២ ដល់ ទី៦
២
ចំលងតារាងទិន្នន័យ ៥ក ទៅលើក្ដារឆ្នួនហើយគូស
តារាងទៅតាមទំហំផ្សេងៗ ។
FISH ABUNDANC
SITE
OBSERVER
FAMILY
SIZES
LAPULAPU
MAYAMAYA
LIPTI
KATAMBAK
TALAKITOK
៣
ដាក់ខ្សែម៉ែត្រទៅតាមសណ្ឋានបាតសមុទ្រ និងក្នុង
ជំរៅទឹកកំណត់មួយ ។ ហើយកត់ត្រាជំរៅទឹក ។
៤
រង់ចាំពី ១០-១៥ នាទី ដើម្បីអោយត្រីត្រលប់មក
កន្លែងដើមវិញ ចូរប្រយ័ត្នកុំបង្អើលត្រីនៅពេលធ្វើការអង្កេត
5 TO 7m.
(15 TO 20 FT.)
FROM SURFACE
៥
អ្នកអង្កេតម្នាក់ៗត្រូវចាប់ផ្ដើមអង្កេតពីដើមខ្សែម្ខាង ដោយបណ្ដែតខ្លួនទៅតាមខ្សែម៉ែត្រម្ខាងរាងៗខ្លួននៅខណៈ
ពេលធ្វើការអង្កេតតាមទទឹងខ្សែម៉ែត្រ ៥ម និងឆ្លោះទៅតាម បណ្ដោយខ្សែដែលមានចំនុចក្រិត ៥ម ។

**៦** អ្នកអង្កេតទាំងពីរនាក់ហែលទៅមុខនិងឈប់ក្នុងចន្លោះប្រវែង ៥មម្តង១ ដើម្បីកត់ត្រាចំនួនត្រីតាមតំបន់ដែលបានអង្កេតរហូតដល់ចប់ខ្សែម៉ែត្រ ។ ជាទូទៅគេរាប់ត្រីដែលហែលលឿនមុនត្រីដែលហែលយឺត ។ ខ្សែម៉ែត្រនីមួយ១គ្រប់ដណ្តប់ក្រលាផ្ទៃ៥០០ម$^{២}$ (៥០មx១០មទទឹង) ។ ចំនួនត្រីសរុបដែលរាប់បានទាំងសងខាងត្រូវសរសេរចូលទៅក្នុងតារាងទិន្នន័យ **៥ក**



**៧** ចំណាត់ថ្នាក់តំបន់ខ្សែម៉ែត្រទៅតាមគោលបំណងរបស់អ្នកដែលចង់បានទិន្នន័យ ។ ឧទាហរណ៍:




